# កម្មវិធីព្រៃឈើជាតិកម្ពុជា

## សេចក្តីព្រាងលើកទី២

ខែ ឧសភា ឆ្នាំ ២០០៩

# អារម្ភកថា

កម្មវិធីព្រៃឈើជាតិនៃកម្ពុជា ស្តែងឡើងអំពីគោលនយោបាយព្រៃឈើរបស់កម្ពុជា ។ កម្មវិធីព្រៃឈើជាតិជ្រើសរើសមធ្យោបាយមួយចំនួនក្នុងការធ្វើផែនការ ការធ្វើកម្មវិធី និង ការអនុវត្តសកម្មភាពទាក់ទិននឹងព្រៃឈើដោយឈរលើមូលដ្ឋានរួមមួយនៃគោលការណ៍ណែនាំ ។

កម្មវិធីព្រៃឈើជាតិគឺជាផ្លូវមួយដែលរាជរដ្ឋាភិបាលកម្ពុជា មានបំណងប្រើប្រាស់តាមលក្ខណៈស្ថាប័ន និងភាពស្របច្បាប់ដើម្បីសម្រេចអោយបាននូវគោលដៅនៃការអភិវឌ្ឍន៍ព្រៃឈើ ។ កម្មវិធីនេះគឺជាចក្ខុវិស័យរួមអំពីរបៀបគ្រប់គ្រង និង របៀបផ្តល់ប្រយោជន៍ដែលបានមកពីធនធានព្រៃឈើ ។ កម្មវិធីនេះមានការចូលរួមពីស្ថាប័នរដ្ឋាភិបាល សហគមន៍មូលដ្ឋាន វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ អន្តរជាតិ ហើយ និងបុគ្គលក្នុងវិស័យព្រៃឈើ ហើយថាតើគេទាំងនោះធ្វើអន្តរកម្មក្នុងបរិបទនៃការអភិវឌ្ឍន៍ជាតិ ដោយវិធីណា ។

គោលបំណងនៃកម្មវិធីនេះគឺបង្កើតអោយមានជាក្របខ័ណ្ឌសង្គម និងនយោបាយដែលអាចអនុវត្តបានសំរាប់ការគ្រប់គ្រងព្រៃឈើទាំងអស់អោយមាននិរន្តរភាព ។ កម្មវិធីព្រៃឈើជាតិ រួមមានទាំងគោលនយោបាយក៏ដូចជាយន្តការសំរាប់ការអភិវឌ្ឍន៍ ការតាមដាន និងការវាយតំលៃ ។ កម្មវិធីព្រៃឈើជាតិមានបំណងចំណាត់នូវទិសដៅ និងគោលដៅចំពោះការ អភិវឌ្ឍន៍ព្រៃឈើកម្ពុជា និងការគ្រប់គ្រងព្រៃឈើដើម្បីជួយផ្តល់អោយសង្គមរកចំណូលបានច្រើនដោយនិរន្តរភាពរយៈពេលវែងសំរាប់ជីវភាពរស់នៅ និង សំរាប់ការផ្តល់សេវាកម្មបរិស្ថានដើម្បីការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចទាំង មូល ។

ការសន្យារបស់រដ្ឋាភិបាលកម្ពុជាក្នុងការចងក្រងកម្មវិធីព្រៃឈើជាតិ គឺមានចែងច្បាស់លាស់ក្នុងសេចក្តីថ្លែងការណ៍គោលនយោបាយព្រៃឈើជាតិ ឆ្នាំ ២០០៤ ។ សេចក្តីថ្លែងការណ៍នេះបានកត់សំគាល់ទៅលើនីតិវិធីជាក់លាក់នៃកម្មវិធីព្រៃឈើជាតិ ។ ជាលទ្ធផលរាជរដ្ឋាភិបាលសំរេចបានច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២, ការពិនិត្យវាយតំលៃឡើងវិញវិស័យ ព្រៃឈើឯករាជ្យ (IFSR 2004), ការបង្កើតក្រុមការងារបច្ចេកទេសអំពីព្រៃឈើ និងបរិស្ថានក្នុងឆ្នាំ ២០០៤ ហើយនៅចុងក្រោយបង្អស់គឺផែនការសកម្មភាពចំពោះព្រៃឈើ និង បរិស្ថានសំរាប់រយៈកាល ២០០៧-២០១០ ។ លេខាធិការដ្ឋាននៃកម្មវិធីព្រៃឈើជាតិត្រូវបានស្ថាបនាឡើងនៅចុងឆ្នាំ ២០០៧ ដែលជាវេទិកាមួយសំរាប់អ្នកពាក់ព័ន្ធបន្តធ្វើការចរចា ហើយនិងចូលរួមក្នុងនីតិវិធីកម្មវិធីព្រៃឈើជាតិ ។

មានស្ថាប័ន និងអ្នកពាក់ព័ន្ធជាច្រើនដែលបានផ្តល់វិភាគទានដ៏មានតំលៃដល់ការចងក្រងកម្មវិធីព្រៃឈើជាតិបច្ចុប្បន្ននេះ ។ យើងមានសេចក្តីសង្ឃឹមថាកម្មវិធីព្រៃឈើជាតិកម្ពុជា និងនីតិវិធីបន្តនៃដំណើរការកម្មវិធីនេះនឹងផ្តល់វិភាគទាន ចំពោះការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពឆ្ពោះទៅរកការអភិរក្សធនធានព្រៃឈើអភិបាលកិច្ចល្អ ការ អភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ហើយនិងការកាត់បន្ថយភាពក្រីក្រ ។

**ទម្រង់នៃឯកសារនេះ**

- ឯកសារនៃកម្មវិធីព្រៃឈើជាតិនៃកម្ពុជាត្រូវបានរៀបរៀងជាផ្នែក ។
- ឯកសារនេះគឺជាគម្រោងយុទ្ធសាស្រ្តទូទៅ រៀបចំតាមអាទិភាពនៃកម្មវិធីដោយមានការពិពណ៌នាខ្លីៗ។ ឯកសាររួមទាំងកម្មវិធីអាទិភាពនីមួយៗត្រូវបានពិនិត្យឡើងវិញតាមរយៈការធ្វើពិគ្រោះយោបល់រាល់ ៥ឆ្នាំម្តង ។
- ឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយឯកនេះផ្តល់នូវសារិតា និងព័ត៌មានបន្ថែមចំពោះកម្មវិធីព្រៃឈើជាតិ ។ ឧបសម្ព័ន្ធទាំងនេះនឹងត្រូវរៀបចំកែសំរួលជារៀងរាល់ឆ្នាំដោយក្រុមការងារបច្ចេកទេសស្តីពីព្រៃឈើ និងបរិស្ថាន ។
- មានឯកសារដែលរៀបរាប់អំពីកម្មវិធីអាទិភាព ហើយដែលកម្មវិធីទាំង៦នេះគឺជាផ្នែកសំខាន់បំផុតនៃកម្មវិធីព្រៃឈើជាតិ : ១) ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការចុះបញ្ជីកាព្រៃឈើជាតិ ។ ២) ការគ្រប់គ្រង និង ការអភិរក្សធនធានព្រៃឈើ ។ ៣) ការពង្រឹងការអនុវត្តន៍ច្បាប់និងអភិបាលកិច្ចព្រៃឈើ ។ ៤) កម្មវិធីសហការព្រៃឈើ ។ ៥) ការពង្រីកសមត្ថភាពនិងការស្រាវជ្រាវ ។ ៦) កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ ។

នៅឯកសារមួយចំនួនទៀតដែលត្រូវរៀបរៀងឡើងដើម្បីកំណត់ថា តើធ្វើយ៉ាងណាធានាតម្លាភាពតាមរយៈនៃការតាមដាន និង ចែកចាយពតិមានអំពីដំណើរការនៃកម្មវិធីព្រៃឈើជាតិ និង គោលដៅយុទ្ធសាស្រ្ត ការអភិវឌ្ឍន៍ព្រៃឈើនៅកម្ពុជា ហើយនិងការអនុវត្តន៍កម្មវិធី ។

**សេចក្តីថ្លែងអំណរគុណ**

មានអង្គការកម្ពុជា ស្ថាប័ន និងមនុស្សជាច្រើនបានធ្វើវិភាគទានចំពោះការរៀបចំកម្មវិធីនយោបាយជាតិ ជាពិសេស ឯកឧត្តម ទី សុគន្ធ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងជាប្រធានរដ្ឋបាលព្រៃឈើ ព្រមទាំងប្រធានក្រុមការងារនៃកម្មវិធីព្រៃឈើជាតិគឺ ឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ ។

ម្ចាស់ជំនួយអន្តរជាតិមួយចំនួនរួមទាំងអង្គការ DANIDA, FAO, Worl Bank, JICA, GTZ និង ITTO ចាប់ពីទសវត្សន៍ឆ្នាំ១៩៩០បានគាំទ្រតាមគ្រប់មធ្យោបាយលើការអភិវឌ្ឍន៍នយោបាយព្រៃឈើនៅកម្ពុជា ។ ជាមួយគ្នានេះដែរមានគម្រោងជាច្រើនរបស់អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នដៃគូបានផ្តល់វិភាគទានដល់ការសិក្សាវិភាគលំអិត និង ទិន្នន័យបន្ថែម ។

ឯកសារនៃការវាយតម្លៃវិស័យព្រៃឈើ " (Forest Sector Review) IFSR (IFSR 2004) និងឯកសារសំយោគ "មួយទសវត្សន៍នៃផែនការ និងការគ្រប់គ្រងព្រៃឈើនៅកម្ពុជា " (FA 2007) ត្រូវបានប្រើប្រាស់ជាពិសេសក្នុងការប្រមូល និង ការចងក្រងទិន្នន័យ (យោបល់សំរាប់កែប្រែតម្លៃពិសេសដើម្បីកំណត់អត្តសញ្ញាណនៃបញ្ហាធំៗនៃកម្មវិធីព្រៃឈើជាតិត្រូវឆ្លើយតប) ។

ភារកិច្ចនៃការបង្កើត និងការធ្វើការវិភាគទិន្នន័យ ហើយនិងការរៀបចំ និងកែសំរួលកម្មវិធីព្រៃឈើជាតិមានអ្នកមានការទទួលខុសត្រូវខ្ពស់ចូលរួមជាច្រើន ។ វាជាការសោកស្តាយដែលយើងមិនអាចថ្លែងអំណរគុណមនុស្សដែលបានធ្វើវិភាគទានដល់ការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិអោយបានគ្រប់ៗគ្នា ។ យើងសូមស្រង់ឈ្មោះមនុស្សសំខាន់ៗដែលបានចូលរួមទុកក្នុងបញ្ជីខាងក្រោម ។

## ក្រុមការងារស្នូលនៃកម្មវិធីព្រៃឈើជាតិ

ឯកឧត្តម ជា សំអាង ប្រធានកម្មវិធីព្រៃឈើជាតិ (រដ្ឋបាលព្រៃឈើ), លោក ឆេង គឹមស៊ុន (រដ្ឋបាលព្រៃឈើ), បណ្ឌិត សុខ ហេង (អ្នកសម្របសម្រួលកម្មវិធី), Mr. Arvid Sloth (FLD), Mr. Jacob K. Jebson (DANIDA), លោក ឡាយ ឃីម (UNDP), Ms. Van Xiajie (FAO), Dr. Peter Jipp (WB), លោក ជួប ប៉ារីស (FAO), លោក ឡាយ ឃីម (ឈុំ សុវណ្ណី) (UNDP) និង លោក ហង់ ស៊ុនត្រា (រដ្ឋបាលព្រៃឈើ) ។

**តារាងសមាជិកក្រុមកម្មវិធីព្រៃឈើជាតិ :**

| ល.រ | ឈ្មោះ | អង្គភាព/អង្គការ |
|---|---|---|
| ១ | ឯកឧត្តម ជា សំអាង (ប្រធាន) | រដ្ឋបាលព្រៃឈើ |
| ២ | បណ្ឌិត សុខ ហេង | ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន |
| ៣ | (អ្នកសម្របសម្រួល) | តំណាងរដ្ឋបាលព្រៃឈើ |
| ៤ | លោក ឆេង គឹមស៊ុន | ដានីដា តំណាងដៃគូអភិវឌ្ឍន៍ |
| ៥ | លោក Jacob K. Jebson | ប្រធានសមាគមន៍ពាណិជ្ជកម្ម និងឧស្សាហកម្មកម្ពុជា |
| ៦ | លោក លូ ឈូឆាង | ព្រៃឈើ និងទេសភាព ប្រទេសដាណឺម៉ាក្ស-មជ្ឈមណ្ឌលព្រៃ |
| | លោក Arvid Sloth | ឈើ និងទេសភាព និងផែនការដាណឺម៉ាក្ស សាកលវិទ្យាល័យ |
| | | កូផេនហាហ្គេន |
| ៧ | លោក ថម អីវ៉ាន | សង្គមអភិរក្សសត្វព្រៃ តំណាងអង្គការអន្តរជាតិ |
| ៨ | បណ្ឌិត សារ៉េត បូរ៉ាមី | ក្រសួងគ្រប់គ្រងដែនដី ផែនការនគររូបនីយកម្ម និងសំណង់ |
| ៩ | លោក សុខ វង្ស | ក្រសួងបរិស្ថាន |
| ១០ | បណ្ឌិត រុន រ័តវាសនា | ក្រសួងមហាផ្ទៃ |
| ១១ | លោក នេត មុន្នី | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១២ | លោក សាតូ | ទីភ្នាក់ងារដៃគូសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| ១៣ | បណ្ឌិត Peter Jipp | ធនាគារពិភពលោក |
| ១៤ | លោកស្រី គីមីកូ អ៊ូណូ | អង្គការចំណីអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ |
| ១៥ | លោក អ៊ីវ៉ាន បាសក្កូវ៉ | GERESS អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |

| | | |
|---|---|---|
| ១៦ | លោក ជេម បេមផុន | មជ្ឈមណ្ឌលបណ្ដុះបណ្ដាលសហគមន៍ព្រៃឈើតំបន់អាស៊ីប៉ាស៊ីភិក |
| ១៧ | លោក ហង់ ស៊ុនត្រា | រដ្ឋបាលព្រៃឈើ |
| ១៨ | លោក ឃន សាវ៉េត | រដ្ឋបាលព្រៃឈើ |
| ១៩ | លោក សួន សុវណ្ណ | រដ្ឋបាលព្រៃឈើ |
| ២០ | លោក ញឹក រតនៈពេជ្រ | រដ្ឋបាលព្រៃឈើ |

**អនុក្រុមការងារ**

**១). ការកំណត់ព្រំប្រទល់ព្រៃឈើជាតិ ការចាត់ថ្នាក់ និងការចុះបញ្ជីកា — ២). ការគ្រប់គ្រងធនធានព្រៃឈើ និង កម្មវិធីអភិរក្ស :**

ឯកឧត្តម ជា សំអាង (រដ្ឋបាលព្រៃឈើ), លោក ឆេង គីមស៊ុន (រដ្ឋបាលព្រៃឈើ), លោក ភីតទ័រ ជីប (ធនាគារពិភពលោក), លោក មាស មករា (រដ្ឋបាលព្រៃឈើ), លោក ឃន សាវ៉េត ( រដ្ឋបាលព្រៃឈើ), ឯកឧត្តម ថន សារ៉ាត់ (រដ្ឋបាលព្រៃឈើ), លោក ហង់ ស៊ុនត្រា (រដ្ឋបាលព្រៃឈើ), លោក ម៉ែន ភិមៀន (រដ្ឋបាលព្រៃឈើ), លោក ញឹក រតនៈពេជ្រ (រដ្ឋបាលព្រៃឈើ), លោក ឈាង ដានី (រដ្ឋបាលព្រៃឈើ), លោក ប៉ក់ ជាលី (រដ្ឋបាលព្រៃឈើ), លោក ប៊ុន វណ្ណា (រដ្ឋបាលព្រៃឈើ), លោក អួន សំអុល (រដ្ឋបាលព្រៃឈើ), លោក នេត មុន្នី (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ), លោក លូ ឈូឆាង (CTIA), លោក ថម អីវ៉ាន (WCS), បណ្ឌិត សាវ៉េត បូរ៉ាមី (ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់) ។

**៣). ការអនុវត្តន៍ច្បាប់ស្ដីពីព្រៃឈើ និងកម្មវិធីអភិបាលកិច្ច**

លោក សៀ វ៉ា (រដ្ឋបាលព្រៃឈើ), លោក សួន សុវណ្ណ (រដ្ឋបាលព្រៃឈើ), ឯកឧត្តម ទឹម ស៊ីផា (រដ្ឋបាលព្រៃឈើ), ឯកឧត្តម វណ្ណ សូផាណ្ណា (រដ្ឋបាលព្រៃឈើ), លោក អៀង សាវ៉េត (រដ្ឋបាលព្រៃឈើ) ។

**៤). កម្មវិធីសហគមន៍ព្រៃឈើជាតិ**

ឯកឧត្តម ទី សុគន្ធ (រដ្ឋបាលព្រៃឈើ), លោក ជេម បេមផុន (RECOFTC), លោក ឡាវ សេដ្ឋាផល (រដ្ឋបាលព្រៃឈើ), បណ្ឌិត សុខ ហេង, លោក សូត្រ អុន (រដ្ឋបាលព្រៃឈើ), លោក ឡុង រតនៈកុមារ (រដ្ឋបាលព្រៃឈើ), កញ្ញា វង្ស សុបញ្ញា (រដ្ឋបាលព្រៃឈើ), លោក ឈិត សំអាត (NGO Forum), លោក អ៊ីវ៉ាន បាសកូវ៉ូ (GERES) ។

**៥). ការពង្រឹងសមត្ថភាព និងកម្មវិធីស្រាវជ្រាវ**

លោក ចាន់ សុផល (រដ្ឋបាលព្រៃឈើ), លោក ជីប ប៊ុនថារិន (រដ្ឋបាលព្រៃឈើ), បណ្ឌិត ប៉ក់ កាណាដា (រដ្ឋបាលព្រៃឈើ), លោក សិរិត វណ្ណា (រដ្ឋបាលព្រៃឈើ), លោក នុត សុធា (រដ្ឋបាលព្រៃឈើ), លោក ប៊ុន រ៉ាដា (រដ្ឋបាលព្រៃឈើ), លោក ឡាយ ឃីម (UNDP), លោក ស៊ឹម ស៊ីសុខាលី (MIME), លោក អារីត ស្លុត (FLD) ។

**៦). កម្មវិធីវិនិយោគទុនសំរាប់វិស័យព្រៃឈើ**

ឯកឧត្តម អ៊ុង សំអាត (រដ្ឋបាលព្រៃឈើ), លោក ម៉ា សុខថា (រដ្ឋបាលព្រៃឈើ), ឯកឧត្តម ថន សារ៉ាត (រដ្ឋបាលព្រៃឈើ), លោក សេង ស៊ុនណារុន (រដ្ឋបាលព្រៃឈើ), លោក ឃុន វឌ្ឍនា (រដ្ឋបាលព្រៃឈើ), លោក ព្រាប សំ (រដ្ឋបាលព្រៃឈើ), លោក ប៊្រុន ស្តេហ្វាន (ADF) ។

**៧). ក្រុមគាំទ្រកម្មវិធីព្រៃឈើជាតិរឹងមាំ**

ឯកឧត្តម ជា សំអាង (រដ្ឋបាលព្រៃឈើ), បណ្ឌិត សុខ ហេង (រដ្ឋបាលព្រៃឈើ), លោក អាវីត ស្លុត (FLD), លោក ឆេង គីមស៊ុន (រដ្ឋបាលព្រៃឈើ), លោក ចាកុប ខេ ជេបសុិន (DANIDA), លោក ហ្វាន ស៊ាវជី (FAO), លោក ឡាយ ឃីម (UNDP), លោក ប៉ារីស ជួប (FAO), លោក ភីតទ័រ ជីប (WB), លោក ហង់ ស៊ុនត្រា (រដ្ឋបាលព្រៃឈើ) ។

**ជំនួយការសម្រួលការងារ**

មជ្ឈមណ្ឌលព្រៃឈើ និងទេសភាព ដាណឺម៉ាក្ស តំណាងដោយលោក អាវីត ស្លុត ។

# មាតិការឿង

អារម្ភកថា

ពាក្យសរសេរកាត់

១. បរិបទ

២. ព្រៃឈើនៅកម្ពុជា

២.១ សេចក្តីសង្ខេបអំពីប្រវត្តិថ្មីៗនៃព្រៃឈើនៅកម្ពុជា

២.២ អភិបាលកិច្ចព្រៃឈើនៅកម្ពុជា

២.៣ កាតព្វកិច្ចអន្តរជាតិ

២.៤ បញ្ហាប្រឈមធំៗក្នុងការគ្រប់គ្រងព្រៃឈើ

២.៥ ដី និងព្រៃឈើ-ការប្រជែងដាច់ណាត់ចំពោះព្រៃឈើកម្ពុជា

២.៦ ឈើ និង អនុផលព្រៃឈើ

២.៧ ព្រៃឈើ និងវិបត្តិអាកាសធាតុ

៣. ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

៤. កម្មវិធីព្រៃឈើជាតិកម្ពុជា

៤.១ ចក្ខុវិស័យ និងបេសកកម្មនៃព្រៃឈើ និងវិស័យព្រៃឈើកម្ពុជា

៤.២ ការរៀបចំដំណើរការអភិវឌ្ឍន៍ ការអនុវត្តន៍ និងការពិនិត្យឡើងវិញអំពីកម្មវិធីព្រៃឈើជាតិ

៥. ទិសដៅយុទ្ធសាស្ត្រ និង ជំហាននៃកម្មវិធីព្រៃឈើជាតិ

ស្ថាប័ន និងអភិបាលកិច្ច

សេដ្ឋកិច្ច

ការយកចិត្តទុកដាក់អំពីវិស័យសង្គមកិច្ច វប្បធម៌ និងបរិស្ថាន

គោលនយោបាយដែលផ្តល់លក្ខខណ្ឌប្រកប

ស្ថានភាពដែលផ្តល់លក្ខខណ្ឌប្រកប

៥.១ ជំរើសគ្រប់គ្រងទៅអនាគត

ជំហានដំបូងមួយចំនួនក្នុងការគ្រប់គ្រងព្រៃឈើ

៥.២ ការតាមដាន និងតម្លាភាព

៥.៣ ការពង្រឹងសមត្ថភាព

៦. កម្មវិធីការងារនៃកម្មវិធីព្រៃឈើជាតិ

ឧបសម្ព័ន្ធ១

ព្រៃឈើកម្ពុជា-ការពិត និងតួលេខ
ឧបសម្ព័ន្ធ២
អភិបាលកិច្ចព្រៃឈើ
ក្របខ័ណ្ឌគោលនយោបាយទូទៅ
នីតិកម្ម និងរដ្ឋបាល
វិមជ្ឈការ និងសហវិមជ្ឈការ
ច្បាប់ភូមិបាល
ដីសម្បទាន
នយោបាយដីធ្លី
ច្បាប់ស្តីពីព្រៃឈើ
ច្បាប់ស្តីពីតំបន់ការពារ
ច្បាប់ស្តីពីការការពារបរិស្ថាន និងធនធានធម្មជាតិ
យុទ្ធសាស្ត្រជាតិស្តីពីជីវចម្រុះ និងផែនការសកម្មភាព (២០០២)
អនុសាសន៍បានពីការពិនិត្យវាយតម្លៃឯករាជ្យលើវិស័យព្រៃឈើ
ការសិក្សាទាំងឡាយទាក់ទងទៅនឹងវិស័យព្រៃឈើកម្ពុជា ១៩៩៦-២០០៧
ការចាត់ថ្នាក់ដីព្រៃ និងជីវិភាជន៍
អភិបាលកិច្ចព្រៃឈើ ការរកឃើញ និងការផ្តល់អនុសាសន៍សំខាន់ៗទាក់ទងទៅនឹងការធ្វើចំណាត់ថ្នាក់ និងការផ្តល់ដី
ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច
ហិរញ្ញវត្ថុ និងចលនាធនធានមនុស្ស
ជំរើសការគ្រប់គ្រងទៅអនាគត
សេចក្តីសង្ខេប និង ការចង្អុលបង្ហាញលើគោលនយោបាយចំពោះការអភិវឌ្ឍន៏វិស័យព្រៃឈើ
ឧបសម្ព័ន្ធ៣
ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ
REDD និងយន្តការស្អាត (CDM)
កម្ពុជា និងការប្រែប្រួលអាកាសធាតុ
ឧបសម្ព័ន្ធ៤
កម្មវិធីព្រៃឈើជាតិ

សេចក្តីត្រូវការក្នុងការអភិរក្សកម្មវិធីព្រៃឈើជាតិ
ដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ
វិធីសាស្រ្តដែលបានអនុវត្តកន្លងមក
ការចរចាជាមួយដៃគូអភិវឌ្ឍន៍-ការកំណត់ក្របខ័ណ្ឌ
សិក្ខាសាលាដំបូង
ការសម្របសម្រួលអោយមានពហុភាពនិយម និងការចូលរួម-សិក្ខាសាលាទី២
សិក្ខាសាលាពិគ្រោះយោបល់
ការបង្កើត និងសមាសភាពក្រុមការងារកម្មវិធីព្រៃឈើជាតិ
កម្មវិធីការងារ និងក្រុមការងារនៃកម្មវិធីព្រៃឈើជាតិ
ការរៀបចំផែនការ និងការអនុវត្ត NFP
ឧបសម្ព័ន្ធ៥
ការពង្រឹងសមត្ថភាព
ការដោះស្រាយទំនាស់ និងការបែងចែកផលប្រយោជន៍
ឧបសម្ព័ន្ធ៦
ការអភិវឌ្ឍន៍ស្ថាប័ន និងកិច្ចសហការ
ឯកសារយោង

## ពាក្យសរសេរកាត់

| | |
|---|---|
| ADB | : ធនាគារអភិវឌ្ឍន៍អាស៊ី |
| ARD | : សមាគមន៍សម្រាប់ការអភិវឌ្ឍន៍ជនបទ |
| ASEAN | : សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CBD | : អនុសញ្ញាស្តីពីជីវចម្រុះ |
| CC | : ក្រុមប្រឹក្សាឃុំ |
| CCCO | : ការិយាល័យប្រែប្រួលអាកាសធាតុកម្ពុជា ( ក្រសួងបរិស្ថាន) |
| CCD | : អនុសញ្ញាប្រឆាំងភាពរហោដ្ឋាន |
| CCF | : សហគមន៍អភិរក្សព្រៃឈើ |
| CDCF | : វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CDM | : យន្តការអភិវឌ្ឍន៍ស្អាត (ពិធីការក្យូតូ) |
| COP | : ផែនការអភិវឌ្ឍន៍ឃុំ |
| CDRI | : វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា |
| CF | : សហគមន៍ព្រៃឈើ |
| CFA | : កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ |
| CFMC | : គណៈកម្មាធិការគ្រប់គ្រងសហគមន៍ព្រៃឈើ |
| CFMP | : ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ |
| CFO | : ការិយាល័យសហគមន៍ព្រៃឈើ |
| CFP | : កម្មវិធីសហគមន៍ព្រៃឈើ |
| CIF | : មូលនិធិវិនិយោគឃុំ |
| CITES | : អនុសញ្ញាអន្តរជាតិស្តីពីពាណិជ្ជកម្មនៃប្រភេទក្រុមសត្វ និងក្រុមរុក្ខជាតិព្រៃដែលរងគ្រោះថ្នាក់ |
| CLUP | : ផែនការប្រើប្រាស់ដីធ្លីឃុំ |
| CMDG | : គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា |
| COCHCR | : ការិយាល័យស្នងការសិទ្ធិមនុស្សនៅកម្ពុជា |
| CPF | : សហគមន៍មូលដ្ឋានព្រៃឈើផលិតកម្ម |
| CSD | : គណៈកម្មាការអភិវឌ្ឍន៍ដោយនិរន្តរភាព |
| CTIA | : សមាគមន៍ឧស្សាហកម្ម និងពាណិជ្ជកម្មកម្ពុជា |

| | |
|---|---|
| CTS | : ប្រព័ន្ធតាមដានលំហូរថវិកា |
| CTSP | : គម្រោងគ្រាប់ពូជឈើកម្ពុជា |
| DANIDA | : ភ្នាក់ងារអភិវឌ្ឍប្រទេសដាណឺម៉ាក |
| DFW | : នាយកដ្ឋានរុក្ខាប្រមាញ់ |
| DNA | : អាស៊ីធរជាតិសំរាប់យន្តការអភិវឌ្ឍន៍ស្អាត |
| EIA | : ការវាយតំលៃលើផលប៉ះពាល់បរិស្ថាន |
| EU | : សហភាពអឺរ៉ុប |
| FA | : រដ្ឋបាលព្រៃឈើ |
| FAO | : អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ |
| FLD | : មជ្ឈមណ្ឌលព្រៃឈើ និងទេសភាព ដាណឺម៉ាក សាកលវិទ្យាល័យកូផេនហាហ្គេន |
| FLEGP | : កម្មវិធីការពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច |
| FLEGT | : ការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្ម |
| FMU | : ផ្នែករដ្ឋបាលព្រៃឈើ |
| FRM | : ការគ្រប់គ្រងធនធានព្រៃឈើ |
| FSC | : គណៈកម្មាការវិញ្ញាប័នប័ត្រព្រៃឈើ |
| FWRDI | : វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ |
| GAP | : ផែនការអភិបាលកិច្ច |
| GDCC | : គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ |
| GDP | : ផលទុនសរុបក្នុងស្រុក |
| GFA | : ក្រុមហ៊ុនពិគ្រោះយោបល់អាល្លឺម៉ង់មួយ |
| GIS | : ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| GPS | : ប្រព័ន្ធទីតាំងភូមិសាស្ត្រ |
| GTZ | : ភ្នាក់ងារអភិវឌ្ឍន៍អាល្លឺម៉ង់ |
| Ha | : ហិកតា |
| HAS | : យុទ្ធសាស្ត្រសុខដុមរមនីយកម្ម និងសម្ព័ន្ធមិត្ត |
| ICEM | : មជ្ឈមណ្ឌលអន្តរជាតិគ្រប់គ្រងបរិស្ថាន |
| IFF | : វេទិកាអន្តររដ្ឋាភិបាលស្តីពីព្រៃឈើ |
| IFSR | : ការវាយតម្លៃឯករាជ្យក្នុងវិស័យព្រៃឈើ |
| INGO | : អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |

IPF :
ITTA : កិច្ចព្រមព្រៀងអន្តរជាតិព្រៃឈើតំបន់ត្រូពិក
ITTO : អង្គការអន្តរជាតិព្រៃឈើតំបន់ត្រូពិក
JICA : ទីភ្នាក់ងារជប៉ុនសហប្រតិបត្តិការអន្តរជាតិ
JMI : សូចនាករតាមដានរួម
LIS : ប្រព័ន្ធធានារ៉ាប់រងតាមផ្លូវច្បាប់
MAFF : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
MAR : ការតាមដាន វាយតំលៃ និងរបាយការណ៍
MARPOL : អនុសញ្ញាអន្តរជាតិការពារប្រឆាំងជាតិពុលនៅកន្លែងចាក់សម្រាម-កាកសំណល់ និងវត្ថុផ្សេងៗ
MDG : គោលដៅអភិវឌ្ឍន៍សហវត្សរ៍
MEF : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MIME : ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល (ឧស្សាហកម្មរ៉ែ និងថាមពល)
MLMUPC : ក្រសួងគ្រប់គ្រងដែនដី ផែនការនគររូបនីយកម្ម និងសំណង់
MoE : ក្រសួងបរិស្ថាន
MRC : កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ដោយនិរន្តរភាពនៃអាងទន្លេមេគង្គ
MRV : ការតាមដាន ធ្វើរបាយការណ៍ និងបញ្ជាក់ឡើងវិញ
NACOMFOP : គណៈកម្មាធិការជាតិដើម្បីគ្រប់គ្រង និងអនុវត្តនយោបាយគ្រប់គ្រងព្រៃឈើ
NBSAP : ផែនការ និងយុទ្ធសាស្ត្រជាតិជីវចម្រុះ
NCAS : ប្រព័ន្ធគណនាកោបោនជាតិ
NCFP : កម្មវិធីសហគមន៍ព្រៃឈើជាតិ
NCFPR : គណៈកម្មាធិការជាតិកែទម្រង់នយោបាយព្រៃឈើ
NFDCRP :
NFMP : ផែនការជាតិគ្រប់គ្រងព្រៃឈើ
NFP : កម្មវិធីព្រៃឈើជាតិ
NFPG : នយោបាយព្រៃឈើជាតិ និងគោលការណ៍ណែនាំ
NGO : អង្គការក្រៅរដ្ឋាភិបាល
NPRS : យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ
NRM : ការគ្រប់គ្រងធនធានធម្មជាតិ
NSDP : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

| | |
|---|---|
| NTFP | : អនុផលព្រៃឈើ |
| OECD_DAC | : គណៈកម្មាធិការជំនួយដើម្បីការអភិវឌ្ឍន៍ |
| PA | : តំបន់ការពារ |
| PDR | : សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យ |
| PEFC | : កម្មវិធីគាំទ្រវិញ្ញាបនកម្មព្រៃឈើ |
| PF | : ភាពជាដៃគូវិស័យព្រៃឈើ |
| PFE | : សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ |
| PIP | : កម្មវិធីវិនិយោគសាធារណៈ |
| PLUP | : ផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម |
| R_PIN | : |
| RAMSAR | : អនុសញ្ញាដីសើមសារៈសំខាន់អន្តរជាតិ |
| RECOFTC | : មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើតំបន់អាស៊ីប៉ាស៊ីភិច |
| REDD | : ការកាត់បន្ថយការភាយឧស្ម័នដែលកើតចេញពីការបាត់បង់ព្រៃឈើ និងភាពរេចរឹល |
| ReFOP | : កម្មវិធីព្រៃឈើតំបន់ (អាស៊ាន) |
| RGC | : រាជរដ្ឋាភិបាលកម្ពុជា |
| RSP | : ផែនការយុទ្ធសាស្ត្រចតុកោណ (I & II) |
| SEDPII | : ផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចលើកទី២ |
| SFM | : ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព |
| SGS | : |
| ToT | : វគ្គគរុកោសល្យ |
| TWGF&E | : ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន |
| UNDP | : កម្មវិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNFCCC | : អនុសញ្ញាគំរោងការអង្គការសហភាប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNFF | : វេទិកាអង្គការសហប្រជាជាតិអំពីព្រៃឈើ |
| USAID | : ទីភ្នាក់ងារសហរដ្ឋដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| VPA | : កិច្ចព្រមព្រៀងភាពជាដៃគូស្ម័គ្រចិត្ត |
| WB | : ធនាគារពិភពលោក |
| WCS | : សង្គមអភិរក្សសត្វព្រៃ |
| WTO | : អង្គការពាណិជ្ជកម្មពិភពលោក |

## ១. បរិបទ

កម្មវិធីព្រៃឈើជាតិនៃកម្ពុជា ត្រូវបានអភិវឌ្ឍន៍ស្របតាមគោលការណ៍របស់កម្មវិធីព្រៃឈើជាតិ ដែលបង្កើតឡើងដោយវេទិកាអង្គការសហប្រជាជាតិស្តីពីព្រៃឈើក៏ដូចជាផែនការកាត់បន្ថយភាពក្រីក្រ ហើយនិងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ។

កម្មវិធីនឹងចង្អុលបង្ហាញការអភិវឌ្ឍន៍វិស័យព្រៃឈើកម្ពុជាក្នុងរយៈពេលពីរទសវត្សរ៍ខាងមុខ ហើយនឹងបច្ចុប្បន្នភាព និងពិនិត្យឡើងវិញជាប្រចាំ ។ គោលការណ៍ធំៗដែលបានប្រកាន់ខ្ជាប់នោះរួមមាន :

- ភាពជាម្ចាស់
- ភាពស៊ីសង្វាក់ទៅនឹងវិន័យដទៃទៀត
- ភាពជាដៃគូ និងការចូលរួមទូលំទូលាយ

នៅពេលដែលឯកសារនេះត្រូវបានចងក្រងជារូបរាងឡើងលើកទី១ក្នុង ឆ្នាំ ២០០៩ មានបញ្ហាពិភពលោកធំៗចំនួនពីរដែលបានជះឥទ្ធិពលលើការយល់ឃើញរបស់មនុស្សចំពោះព្រៃឈើ និងលើវិធីសាស្ត្រគ្រប់គ្រងព្រៃឈើ ។ ក្នុងនោះគឺវិបត្តិសេដ្ឋកិច្ចពិភពលោកដែលបានកើតឡើងមិនដឹងថាពេលណាត្រូវចប់ នោះមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលគេមិនអាចមើលឃើញក្នុងរយៈពេលច្រើនទសវត្សរ៍ខាងមុខ ។ វិបត្តិនេះនឹងប៉ះពាល់ការការងារធ្វើហើយ ច្បាស់ទៅទៀតនោះតំរូវការចំណីអាហារ ពិសេសប្រជាជនស្ថិតក្នុងតំបន់ជនបទក្រីក្រងាយរងផលប៉ះពាល់ ។ នៅកម្ពុជាវិស័យសំខាន់ៗមានវិស័យកាត់ដេរ សេវាកម្មទេសចរណ៍ និង មានការបាត់បង់ការងាររាប់ម៉ឺនក្នុងរយៈពេលដ៏វែងឬដ៏ខ្លី ។ ក្នុងស្ថានភាពនេះព្រៃឈើអាចបំរើជាប្រភពពីរគឺ អាហារ និង ការងារបើសិនជាគ្រប់គ្រងវាអោយបានល្អ ។

វិបត្តិអាកាសធាតុ លាតត្រដាងអោយឃើញយ៉ាងឆាប់រហ័សនូវភាពកាន់តែអាក្រក់ជាងអ្វីៗដែលបានរំពឹងទុកពីពេលមុន ។ វិធានការណ៍ដែលមនុស្សត្រូវធ្វើដើម្បីទប់ទល់វិបត្តិនេះត្រូវបានកំណត់ចេញជារូបរាង ហើយមានសេចក្តីអំពាវនាវកាន់តែខ្លាំងឡើងដើម្បីអនុវត្តវិធានការណ៍ទាំងនេះ ។ នៅពេលព្រៃឈើ និងមុខងាររបស់វាក្នុងការស្រូប និងបញ្ចេញជាតិកាបោន កំពុងត្រូវបានគេអារម្មណ៍យ៉ាងខ្លាំង ។ ទន្ទឹមនឹងនេះ ការប្រែប្រួលអាកាសធាតុជះឥទ្ធិពលដល់ប្រព័ន្ធបរិស្ថាន កម្ពុជា រួមទាំងព្រៃឈើផងដែរ ។ អាកាសធាតុមានឥទ្ធិពលជ្រៅជ្រះទៅលើ បរិស្ថាន សេដ្ឋកិច្ច និង សង្គម ។

កម្ពុជាសម័យទំនើបដែលទើបតែងើបពីវិនាសកម្មនៃសង្គ្រាមស៊ីវិល និង ការប្រល័យពូជសាសន៍បានតស៊ូហើយកំពុងតស៊ូអោយមានអភិបាលកិច្ចល្អ របៀបរៀបរយក៏ដូចជាខិតខំកសាងសមត្ថភាពធនធានមនុស្សផងដែរ ។ អភិបាលកិច្ចល្អបានក្លាយជាមូលបទ (ធាតុដ៏សំខាន់) ដ៏សំខាន់ក្នុងផែនការរដ្ឋាភិបាល នឹងក្នុងទំនាក់ទំនងជាមួយ

ដៃគូអភិវឌ្ឍន៍អន្តរជាតិ និង ទីភ្នាក់ងារអង្គការសហប្រជាជាតិ ។ វាក៏ជាមូលដ្ឋានដ៏សំខាន់ផងដែរក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលលើកទី២ ហើយជាគោលការណ៍សំខាន់មួយក្នុងកម្មវិធីនយោបាយ ឆ្នាំ ២០០៨ ។

**ចំនុចអភិបាលកិច្ចល្អៗដែលមានឥទ្ធិពលលើព្រៃឈើគឺ :**

- តម្លាភាពក្នុងអភិបាលកិច្ចល្អ និងការគ្រប់គ្រង
- ការចូលរួមពីសាធារណៈ
- ការសម្របសម្រួលអន្តរស្ថាប័ន
- ការប្រកាន់ខ្ជាប់ចំពោះច្បាប់ និងការពង្រឹងការអនុវត្តច្បាប់

ឯកសារកម្មវិធីព្រៃឈើជាតិដែលនឹងបោះពុម្ពលើកទី១នេះ នឹងស្វែងរកការប្រមើលមើលនូវបច្ច័យទាំងឡាយដែលកើតចេញពីព្រឹត្តការណ៍ពិភពលោក ហើយស្ថានភាពជាក់ស្តែងនៃព្រៃឈើកម្ពុជាទៅលើវិធីសាស្ត្រទាំងឡាយសំដៅតើធ្វើអោយបានប្រសើរឡើងនូវអភិបាលកិច្ច និងការគ្រប់គ្រងព្រៃឈើ ។ ដូច្នេះមុននឹងពិនិត្យលើចំណុចនេះយើងត្រូវស្វែងយល់ជាមុនថា" នៅប្រទេសកម្ពុជាព្រៃឈើមានន័យយ៉ាងណាខ្លះ " ។

**សេចក្តីថ្លែងការណ៍របស់កម្ពុជាអំពីកម្មវិធីព្រៃឈើជាតិ**

រាជរដ្ឋាភិបាលកម្ពុជាប្រកាសជាឱឡារិកថា ខ្លួនកំពុងប្តេជ្ញាចិត្តក្នុងដំណើរការអភិវឌ្ឍន៍ និងការអនុវត្តន៍កម្មវិធីព្រៃឈើជាតិក្នុងគោលបំណងនាំមកនូវអភិបាលកិច្ចល្អ ហើយនិងភាពជាដៃគូដែលកម្មវិធីនឹងក្លាយជាកំលាំងធាតុដ៏សំខាន់សំរាប់ជួយដល់ការគ្រប់គ្រងព្រៃឈើនៅកម្ពុជាអោយមាននិរន្តរភាពនៅពេលអនាគត ។

រដ្ឋាភិបាលកម្ពុជាសន្យាថានឹងសំរេចអោយបានពេញលេញនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួនដែលជាមូលដ្ឋានដ៏រឹងមាំសំរាប់ការអភិវឌ្ឍន៍ ។

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជានឹងដើរតួនាទីជាប្រទីបសំរាប់កម្មវិធីព្រៃឈើជាតិ តាមរយៈគោលដៅលុបបំបាត់ភាពក្រីក្រ ធានានិរន្តរភាពបរិស្ថាន និងធានារក្សាគម្របព្រៃឈើអោយបាន៦០% ។

កម្មវិធីព្រៃឈើជាតិនឹងផ្តល់នូវដំណើរការមួយដោយមានការចូលរួមដោយតម្លាភាពក្នុងការរៀបចំផែនការ ការអនុវត្តន៍ហើយ និងការវាយតំលៃលើគ្រប់សកម្មភាពព្រៃឈើ និងកំណត់បង្ហាញទិសដើម្បីដំណោះស្រាយនូវបញ្ហាធំៗក្នុងវិស័យព្រៃឈើ អោយស្របការងារអាទិភាពជាតិ និងមានភាពសុខដុមជាមួយវិស័យឯទៀតៗក្នុងសេដ្ឋកិច្ចជាតិ ។

" សេចក្តីថ្លែងការណ៍គោលនយោបាយវិស័យព្រៃឈើជាតិ ២០០២ " និង " ផែនការយុទ្ធសាស្ត្រអភិវឌ្ឍនជាតិ ២០០៦-២០១០ " បានបង្ហាញអោយឃើញនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការអភិវឌ្ឍន៍ កម្មវិធីព្រៃឈើជាតិ ។ ចក្ខុវិស័យនៃសេចក្តីថ្លែងការណ៍គោលនយោបាយវិស័យព្រៃឈើជាតិនិងបង្កើតជាទម្រង់មូលដ្ឋានមួយក្នុងការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិនេះ :

" រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថា ការអភិរក្ស និងការអភិវឌ្ឍន៍ធនធានព្រៃឈើ បរិស្ថាន សង្គម និង សេដ្ឋកិច្ចដោយគឺជាគ្រឹះមួយយ៉ាងធំសំរាប់សុខមាលភាពសាធារណៈដែលជួយធ្វើវិភាគទានដល់ការការពារបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច " ។

**កម្មវិធីព្រៃឈើជាតិប្រកាន់ខ្ជាប់នូវគោលការណ៍ដូចខាងក្រោម :**

- ការអភិវឌ្ឍន៍ព្រៃឈើដោយនិរន្តរភាពដោយធានានូវផលប្រយោជន៍ សេដ្ឋកិច្ច-សង្គម វប្បធម៌ និង បរិស្ថាន ។
- ភាពជាម្ចាស់ប្រទេសដោយរួមមានការសន្យា ការទទួលខុសត្រូវ ភាពជាម្ចាស់ នឹងស៊ីសង្វាក់ជាមួយគោលនយោបាយជាតិ និងភាពសុខដុមជាមួយម្ចាស់ជំនួយ ។
- មានការចូលរួមតាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាជាមួយក្រុមការងារបច្ចេកទេស អ្នកជំនួយការបច្ចេកទេស ហើយនិងដៃគូនានា ។
- ភាពស៊ីសង្វាក់ទៅនឹងវិស័យពាក់ព័ន្ធការសហការជាមួយក្រសួងនានា អាជ្ញាធរមូលដ្ឋាន ហើយនិងសង្គមស៊ីវិល ។
- មានយន្តការកែសំរួលជាប្រចាំដើម្បីអោយសមស្របតាមសភាពការណ៍ជាក់ស្តែង ។
- មានយន្តការតាមដានលើការអនុវត្តន៍កម្មដើម្បីកែសំរួលអោយបានប្រសើរឡើង ហើយនិងមានយន្តការផ្តល់ព័តិមានសាធារណៈ ។
- មានយន្តការបង្កើនការយល់ដឹងតាមរយៈអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិល ។

**ស្ថិតនៅក្រោមគោលការណ៍នេះកម្មវិធីព្រៃឈើជាតិនឹងរួមមានធាតុសំខាន់៧ដូចតទៅ :**

- សេចក្តីថ្លែងការណ៍អំពីកម្មវិធីព្រៃឈើជាតិ
- ការពិនិត្យឡើងវិញអំពីវិស័យព្រៃឈើ
- ការអភិវឌ្ឍន៍ស្ថាប័ន និងលិខិតបទដ្ឋានច្បាប់
- ឯកសារគោលកម្មវិធីព្រៃឈើជាតិ (ឯកសារនេះ)
- កម្មវិធីនិងអនុកម្មវិធីការងារ (គ្រោងការណ៍ប្រតិបត្តិជាយុទ្ធសាស្ត្រ និង ផ្នែកដែលត្រូវយកចិត្តទុកដាក់ពិសេស)
- យន្តការការចូលរួម និងការដោះស្រាយទំនាស់
- ប្រព័ន្ធតាមដាន និងវាយតំលៃ

សូមអោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសេចក្តីរីករាយបង្ហាញជូន ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិនូវការងារអទិភាព និងភាពចាំបាច់ក្នុងការរៀបចំអោយមាន "ផែនការមួយរយៈពេលវែង និងក្របខ័ណ្ឌនយោបាយដ៏មានតម្លាភាពដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ព្រៃឈើនៅកម្ពុជា" ។

## ២. ព្រៃឈើនៅកម្ពុជា

សំរាប់សង្គមមនុស្សព្រៃឈើបំរើអោយមុខងារធំ២យ៉ាង :

O ព្រៃឈើជាប្រភពនៃជីវភាពរស់នៅ

O ព្រៃឈើមានមុខងារក្នុងប្រព័ន្ធបរិស្ថានដែលមានប្រយោជន៍សំខាន់ដល់មនុស្សលោក ។

ប្រភពនៃជីវភាពរស់នៅ-ព្រៃឈើផ្តល់ឈើសម្រាប់ប្រើប្រាស់ក្នុងការសាងសង់ និងការប្រើប្រាស់ផ្សេងៗទៀត ព្រមទាំងអុសសំរាប់ដុត ។ ព្រៃឈើក៏ផ្តល់ផងដែរនូវចំណីអាហារដោយចំពោះដូចជា គ្រាប់ ផ្លែ មើម សត្វព្រៃ និងប្រភេទផ្សេងៗទៀតសំរាប់មនុស្សជាច្រើន ជាពិសេសចំពោះមនុស្សដែលរស់ នៅជិតព្រៃ ។ ព្រៃឈើក៏ផ្តល់ផងដែរនូវអនុផលដូចជា ថ្នាំសង្កូវ ឬ ជាតិសរសៃអំបោះជាដើម ។ ជីវិតរស់នៅរបស់មនុស្សត្រូវបានទំនុកបម្រុងដោយប្រភពទាំងនេះដោយប្រយោល ឬដោយការផលិតចេញពីរោងចក្រ ឬឧស្សាហកម្មផលិត ដើម្បីបំរើអោយទីផ្សារអ្នកប្រើប្រាស់ ឬក៏ផលិតផលឧស្សាហកម្មបានមកពីផលិតផលព្រៃឈើ ។ នីតិវិធីនៃការគ្រប់គ្រងព្រៃឈើនាពេលខាងមុខអាចផ្តល់អោយនូវការងារធ្វើច្រើនគួរសម ។ នៅកម្ពុជា

សក្តានុពលនៃការបង្កើតការងារក្នុងវិស័យព្រៃឈើ និងចំការឈើ និងក្នុងការទាញយករបស់ឧស្សាហកម្ម គឺស្ថិតនៅក្នុងអាជីវកម្មខ្នះការសន្សំសំចៃ ដោយបោះបង់កាកសំណល់ក្នុងសក្តានុពលដ៏ធំធេង ។ មានតែអភិបាលកិច្ចល្អ ហើយនិងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពប៉ុណ្ណោះទេ ដែលអាចទាញយកកាកសំណល់អស់ទាំងនេះយកមកប្រើប្រាស់ជាផលប្រយោជន៍ក្នុងសេដ្ឋកិច្ចជាតិ ក៏ដូចជាសំរាប់ការកាត់បន្ថយភាពក្រីក្រ ។

មុខងារនៃប្រព័ន្ធបរិស្ថាន-ព្រៃឈើមានសារៈប្រយោជន៍សំរាប់ការប្រព្រឹត្តទៅនៃប្រព័ន្ធបរិស្ថានពិភពលោក ក៏ដូចជាប្រព័ន្ធបរិស្ថានជាច្រើននៅមូលដ្ឋាន ។ ប្រព័ន្ធបរិស្ថានផ្តល់នូវអុកស៊ីហ្សែន ហើយវាស្រូប និងរក្សាទុកកាបោន ។ ព្រៃឈើទាក់ទឹក និងច្រោះទឹក ហើយនិងបញ្ចេញចំហាយទឹកពីក្នុងដី ឬ ពីផ្ទៃដីដែលមានទឹកហូរហៀរ ។ ដូច្នេះមានផលប្រយោជន៍ខ្លាំងចំពោះភពផែនដី ចំពោះតំបន់ ហើយនិងការស្រោចស្រពស្រែ-ចំការ ។ ព្រៃឈើជាជំរក សម្បូណ៌បែបនៃជីវចម្រុះដែលមានសារៈសំខាន់យ៉ាងខ្លាំងដោយត្រង់ចំពោះមនុស្សក៏ដូចជាភាពសម្បូណ៌បែបក្នុងអារម្មណ៍ ។ ព្រៃឈើការពាទេសភាពអោយជៀសផុតពីការហូរច្រោះដែលបំផ្លាញរចនាសម្ព័ន្ធរបស់ដី ។ ព្រៃឈើតាមឆ្នេរសមុទ្រការពារដី និងរចនាសម្ព័ន្ធទប់ទល់និងព្យុះបំផ្លិចបំផ្លាញ ហើយនិងព្រៃលិចទឹកមាត់សមុទ្រ ជាមូលដ្ឋានសំខាន់សម្រាប់ការបង្កាត់ពូជមច្ឆាជាតិ និងសម្រាប់ជីវិតនៃជលជាតិ ។

មកដល់ពេលនេះ

ព្រៃឈើកម្ពុជាផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចដ៏ស្តួចស្តើងតាមរយៈសេវាកម្មប្រព័ន្ធបរិស្ថានទាំងនេះ ទៅអោយអ្នកក្រុង កសិករ ឬសង្គម ព្រោះខ្វះយន្តការនិងទីផ្សារសមស្រមសំរាប់បំរើអោយកិច្ចការនេះនៅឡើយ ។ ជាងនេះទៅទៀតទំនាក់ទំនងរវាងព្រៃឈើធម្មជាតិ និងសកម្មភាពសេដ្ឋកិច្ចរបស់មនុស្សនាពេលបច្ចុប្បន្ន គឺមានលក្ខណៈហុចឱកាសដល់ការបំផ្លិចបំផ្លាញព្រៃឈើ ។ អាជ្ញាធរ រួមទាំងរាជរដ្ឋាភិបាលកម្ពុជា ស្វែងរកការការពារមិនអោយមានការបំផ្លិចបំផ្លាញបែបនេះ ប៉ុន្តែជាញឹកញាយចុះចាញ់ប្រជាជនដែលស្វែងរកចំណូល ឬម្ហូបអាហារ ឬចុះចាញ់គំនាបកំលាំងសេដ្ឋកិច្ចដែលផ្តោតលើប្រាក់ចំណេញភ្លាមៗ ហើយមិនយកចិត្តទុកដាក់ដល់ការប្រើប្រាស់យូរអង្វែងនូវធនធានធម្មជាតិ របស់សង្គមជារួម ។

មានតែការទទួលស្គាល់យ៉ាងខ្លាំងក្លាចំពោះសង្គម-សេដ្ឋកិច្ចនៃតម្លៃដ៏ធំធេងរបស់មុខងារនៃប្រព័ន្ធបរិស្ថានព្រៃឈើ និង តំលៃឯទៀតៗចំពោះព្រៃឈើផ្តល់ផលរយៈពេលវែង ហើយនិងភាពស្របគ្នានូវបទបញ្ជា និងការអនុវត្តន៍នោះទេ ទើបសង្គមចាប់ផ្តើមផលប្រយោជន៍ពេញលេញអំពីគុណប្រយោជន៍នៃអន្តរកម្មនិរន្តរភាពនៃព្រៃឈើ ។ ពេលនោះមុខងារបរិស្ថានព្រៃឈើអាចផ្តល់វិភាគទានចំពោះជីវិតរស់នៅរបស់ប្រជាជនដោយចំពោះ ឬ តាមរយៈការបង្វែរថវិកាជាតិមកវិញ ។

## ២.១ សេចក្តីសង្ខេបអំពីប្រវត្តិថ្មីៗនៃព្រៃឈើកម្ពុជា

ជាប្រពៃណីព្រៃឈើកម្ពុជាបានផ្តល់ ចំណីអាហារ សំភារៈសំណង់ និងថ្នាំពេទ្យ សំរាប់ប្រជាជនមូលដ្ឋាន ដែលជាគោលបំណងរបស់រដ្ឋ ។ ព្រៃលិចទឹក និងព្រៃកោងកាងផ្តល់មូលដ្ឋានបង្កាត់ពូជមច្ឆាជាតិ និងជលជាតិ ហើយព្រៃ កោងកាងក៏ការពារផងដែរនូវឆ្នេរសមុទ្រ ហើយនិងតំបន់ដីដែលស្ថិតនៅពីរក្រោយឆ្នេរនោះ ។

កម្ពុជាមានគំរបព្រៃច្រើនជាងប្រទេសដ៏ទៃ១នៅតំបន់អាស៊ីអាគ្នេយ៍ ។ បច្ចុប្បន្ននេះព្រៃឈើគ្របដណ្តប់ ៦០%លើផ្ទៃប្រទេស ។ តំលៃដ៏ខ្ពស់នៃព្រៃបំរុងទុកតាងអោយទ្រព្យសម្បត្តិដ៏មហាសាល ការប្រើប្រាស់សម្បត្តិនេះ ដោយនិរន្តរភាព និងផ្តល់អោយជាបន្តបន្ទាប់មិនដាច់នូវកំរៃដ៏សមគួរចំពោះសហគមន៍មូលដ្ឋាន ។ ព្រៃឈើអាច ផ្គត់ផ្គង់ផងដែរនូវឈើសំរាប់ឧស្សាហកម្ម ខណៈដែលការប្រើប្រាស់ក្នុងស្រុកក៏ត្រូវការផងទៀត ។

ទោះជាយ៉ាងនេះក៏ដោយ ក៏ទំហំ និងគុណភាពនៃព្រៃឈើកម្ពុជាត្រូវបានថយចុះគួរអោយបារម្ភក្នុងទសវត្សរ៍ ថ្មី១នេះ ។ ផ្ទៃដីដ៏ធំធេងត្រូវបានខូចខាត បណ្តាលមកពីការកាប់ឈើ ភ្លើងឆេះព្រៃ ការដណ្តើមយកដី ការទន្ទ្រាន យកដី ហើយនិងដំណាំពនេចរ មានសភាពរីករាលដាលខ្លាំងឡើងផងដែរ ។

នៅពេលថ្មី១នេះ តំបន់ព្រៃឈើដ៏ធំត្រូវបានប្រែក្លាយទៅជាដីសម្បទានសេដ្ឋកិច្ចច្រើនប្រភេទ ។

មកដល់ទសវត្សរ៍ ឆ្នាំ១៩៧០ ព្រៃឈើត្រូវបានចាត់ថ្នាក់យ៉ាងច្បាស់លាស់មានប្រភេទព្រៃផលិតកម្ម ព្រៃ អភិរក្ស ព្រៃសំរាប់សត្វព្រៃ និងព្រៃសំរាប់សិក្សាស្រាវជ្រាវ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏វាជាប្រព័ន្ធមួយត្រូវ អន្តរធានដោយការជ្រួលច្របល់នយោបាយនៅក្នុងតំណាក់កាលនៃរបបខ្មែរក្រហម ។

នៅទស្សវត្សរ៍ ឆ្នាំ១៩៩០ ប្រព័ន្ធសម្បទានអាជីវកម្មឈើត្រូវបានប្រញាប់ប្រញាល់បញ្ចូលមក ។ អស់រយៈ កាល៤ឆ្នាំ (១៩៩៤-១៩៩៧) រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អោយដីសម្បទានចំនួន ៣៦កន្លែង នៅលើផ្ទៃដី ៧លានហិកតា ប្រមាណជា ៧០% នៃព្រៃឈើ ។ ភាពបំផ្លិចបំផ្លាញរួមគ្នា ទាំងអាជីវកម្មស្របច្បាប់ និងអាជីវកម្ម ល្មើសច្បាប់ហួសសមត្ថភាពនៃមធ្យោបាយកែច្នៃ និងការអនុវត្តន៍ច្បាប់ ហើយនិងការតាមដាននៅខ្សោយ ធ្វើ អោយអន្តរាយដល់ការប្រឹងប្រែងដែលបាញ់ឆ្ពោះទៅរកការគ្រប់គ្រងដោយនិរន្តរភាព ដោយមកពីការយកផល ហួសហេតុនៅខាងក្នុង និងខាងក្រៅតំបន់ព្រៃសម្បទានដែលជាគម្រោងការចង់បានចង់មានឆាប់រហ័សពេក ប៉ុន្តែ ត្រូវបានផលកំរៃតិចទៅវិញ ។ លើសពីនេះ ការហូរចូលនៃចំណូលពីអាជីវកម្មឈើដល់រតនាគារនៃរដ្ឋាភិបាលមាន តិចតួច ។ ក្នុងរយៈកាលនៃការធ្វើអាជីវកម្មដល់កំពូលនៅចុងទស្សវត្សរ៍ឆ្នាំ ១៩៩០ ផលិតផលឈើនាំចេញផ្លូវការ បានបរិច្ចាកស្ទួចស្តើងចំនួន ៤%នៃផលទុនសរុបក្នុងស្រុក (GDP) ។

រាជរដ្ឋាភិបាលបានសំរេចថា គោលដៅតែមួយគត់ចំពោះគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៍របស់កម្ពុជា (៧ បរិស្ថាន) ដើម្បីរក្សាគម្របព្រៃឈើអោយបាន៦០% ពីឆ្នាំ ២០០០ ដល់រង្វង់ឆ្នាំ ២០១៥ ។ នៅឆ្នាំ២០០៨ ការស្ទង់មើល បាន ឃើញថា គម្របព្រៃមានលើសពី៥៩% ដោយអោយអត្ថន័យព្រៃឈើគឺ១០% បុស្សុកគម្រប ទំហំឡូតិ៍តូចបំផុត ០.៥ហិកតា ហើយនិងកំពស់ដើមឈើអប្បបរមា៥ម៉ែត្រ ។

ដើម្បីកែប្រែនិន្នាការនៃការថយចុះទំហំព្រៃឈើ ហើយនិងការធ្វើសេដ្ឋកិច្ចបន្លំ ការបង្អាក់ធ្វើអាជីវកម្ម ត្រូវ បានបង្ហាញអោយឃើញនៅថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០២ ។ ការកែទម្រង់ស្ថាប័នត្រូវបានផ្តើមគំនិតដោយសេចក្តី

ថ្លែងការណ៍នយោបាយព្រៃឈើ និងច្បាប់ថ្មីស្តីពីព្រៃឈើក្នុងឆ្នាំ ២០០២ ។ ការលើកចេញនូវការព្យួរអាជីវកម្មគឺអាស្រ័យទៅលើការរៀបចំ និងការអនុម័តផែនការគ្រប់គ្រងយុទ្ធសាស្ត្រលើព្រៃឈើសម្បទាន ការវាយតម្លៃទៅលើការប៉ះពាល់បរិស្ថាន និងសង្គម ហើយនិងការចរចាឡើងវិញអំពីកិច្ចព្រមព្រៀងលើព្រៃសម្បទាន ។

បច្ចុប្បន្ននេះផ្ទៃដីសម្បទានអាជីវកម្មថយមកនៅ ៣.៥លានហិកតា ដែលជាការសេសសល់តិចតួច ។ ប៉ុន្តែបច្ចុប្បន្ននេះកង្វះផែនការ និងការគ្រប់គ្រងនៅតំបន់មួយចំនួនធំនៃព្រៃឈើបំរុងទុក ហើយនិងតំបន់ការពារមួយចំនួនទៀត ព្រមទាំងការធ្វើអាជីវកម្មល្មើសច្បាប់នៅតែមានបន្ត សំរាប់បំរើអោយទីផ្សារក្នុងស្រុក និងក៏មិនតិចផងដែរចំពោះអតិថិជនវៀតណាម ថៃ ហើយ ចិន ក៏មានគួរសមដែរ ទោះជាមានកិច្ចព្រមព្រៀងថ្នាក់នាយករដ្ឋមន្ត្រីក្នុងការទប់ស្កាត់សកម្មភាពពាណិជ្ជឈើ និងប្រភេទសត្វព្រៃរងគ្រោះឆ្លងដែន ដែលបានចុះហត្ថលេខាជាមួយសាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ប្រទេសថៃឡង់ដ៏ ហើយនិងវៀតណាមក៏ដោយ ។ ព្រៃកោងកាងមួយចំនួនត្រូវបានបំផ្លាញដោយការពង្រីកក្រុងឬកន្លែងកំសាន្ត ឬសំរាប់ជលវប្បកម្ម រីឯព្រៃលិចទឹកជុំវិញបឹងទន្លេសាប ហើយនិងតំបន់លិចទឹកតូចតាចជារៀងរាល់ឆ្នាំនៅតំបន់វាលទំនាបត្រូវបានបំផ្លាញយ៉ាងខ្លាំងដោយការពង្រីកផ្ទៃដីកសិកម្ម ហើយនិងការកាប់ឈើសំរាប់មនុស្សប្រើប្រាស់ ។

ដោយហេតុការណ៍នេះជាតំបន់ធំៗនៃព្រៃឈើច្រើនប្រភេទដែលមានតម្លៃសំរាប់ប្រជាជនមូលដ្ឋាន ហើយនិងសង្គមកម្ពុជា ហើយជាពិសេសសំរាប់ផែនដីទាំងមូល នៅមានសេសសល់មកដល់ឥឡូវនេះ ហើយនិងតំបន់ធំៗដែលព្រៃសម្បទានត្រូវបានបោះបង់ ឬនិយាយមួយបែបគឺព្រៃខូចខាតនៅមានច្រើនដែលត្រូវកែលំអអោយប្រសើរឡើងវិញ ។ ហេតុការណ៍នេះវាតាងអោយឱកាសដ៏ធំធេងផងដែរសំរាប់ប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ។

## ២.២ អភិបាលកិច្ចព្រៃឈើនៅកម្ពុជា

ព្រៃឈើនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយទីភ្នាក់ងារជាច្រើនដូចជា រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ហើយព្រៃកោងកាង និងព្រៃលិចទឹកត្រូវបានគ្រប់គ្រងដោយរដ្ឋបាលជលផល ក្រោមក្រសួងតែមួយ ។ ក្រសួងបរិស្ថានគ្រប់គ្រងតំបន់ការពារ ។

ដូចដែលព្រៃឈើឈរស្ថិតនៅលើដីដែលត្រូវប្រើប្រាស់គ្រប់បែបយ៉ាង ភ្នាក់ងារផ្សេងៗទៀតគឺជាគន្លឹះសំខាន់ក្នុងការគ្រប់គ្រងព្រៃឈើ ។ ភ្នាក់ងារទាំងនោះរួមមានទាំងក្រសួងគ្រប់គ្រងដែនដីផែនការនគររូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។ ថវិកាផ្គត់ផ្គង់ដល់ព្រៃឈើ និងថវិកាបានមកពីព្រៃឈើត្រូវធ្វើនិយ័តកម្មដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជារួមអភិបាលកិច្ចសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីព្រៃឈើ រីឯច្បាប់ស្តីពីតំបន់ការពារដឹកនាំផ្នែកដែលពាក់ព័ន្ធព្រៃឈើ ។ ច្បាប់ស្តីពីតំបន់ការពារបរិស្ថាននិងធនធានធម្មជាតិមានសារៈសំខាន់ខ្លាំងហើយនិងច្បាប់ភូមិបាលធ្វើនិយ័តកម្មដីវិភាជន៍ ដីកម្មសិទ្ធិ និងការគ្រប់គ្រង ។ រដ្ឋបាលខេត្តមានតួនាទីយ៉ាងសំខាន់

ក្នុងផែនការ និង ការអនុវត្តន៍នីតិកម្មទាំងនេះ ។ អគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមឱវាទក្រសួងកសិកម្មគ្រប់គ្រងចំការកៅស៊ូក្នុងរង្វង់ព្រៃសម្បត្តិអចិន្ត្រៃយ៍ ។

នយោបាយនិងគំរោងការនីតិបញ្ញត្តិនៃវិស័យព្រៃឈើមានវិសាលភាពនៅហ្នឹងកន្លែង ។ ទោះជាយ៉ាងនេះក្តីក៏គំរោងការមួយចំនួនមិនទាន់បានបកប្រែអោយទៅជាគោលការណ៍ប្រតិបត្តិជាក់ស្តែងនៅឡើយ ហើយនិងសេចក្តីត្រូវការសមត្ថភាពធនធានមនុស្ស និងស្ថាប័នត្រូវតែពង្រឹង ។ ស្រដៀងគ្នានេះដែរតំបន់ព្រៃឈើដែលមានអន្តរកម្មជាមួយវិស័យផ្សេងៗដូចជា ការស្ថាបនា ការជីកយករ៉ែ ការអភិវឌ្ឍន៍ក្រុង ការពង្រីកកសិកម្ម ការផ្គត់ផ្គង់ទឹកជាដើម ស្ថិតក្នុងសភាពដែលមាននិយ័តកម្មតិចតួចបំផុត ថ្វីបើហេតុការណ៍ដែលបញ្ហាខ្វែងតំបន់ទាំងនេះមានការប៉ះពាល់ទៅលើប្រសិទ្ធភាពនៃអភិបាលកិច្ចទាំងស្រុងក៏ដោយ ។

មានក្រឹត្យច្បាប់មួយចំនួនដែលមានឥទ្ធិពលគួរសមទៅលើអភិបាលកិច្ចព្រៃឈើ ។ ក្នុងចំណោមច្បាប់ទាំងនេះមានច្បាប់ស្តីពីដីសម្បទានសេដ្ឋកិច្ច អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ហើយអនុក្រឹត្យស្តីពីដីសម្បទានសង្គមកិច្ច ។

មកដល់បច្ចុប្បន្ននេះព្រៃឈើឯកជនមិនមានទេនៅកម្ពុជា ។ តំបន់ធំៗនៃសម្បត្តិព្រៃឈើអចិន្ត្រៃយ៍បំរុងទុកគឺជាក់ស្តែងពុំមានការរៀបចំគ្រប់គ្រងទេ ។

អភិបាកិច្ចព្រៃឈើ និងការគ្រប់គ្រង នឹងត្រូវដឹកនាំដោយគម្រោងការជាតិធំៗជាច្រើនដែលមានវិសាលភាពខាងអត្ថន័យ និងគោលដៅព្រៃឈើ :

- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- ផែនការជាតិអភិវឌ្ឍន៍យុទ្ធសាស្ត្រ ២០០៦-២០១០ និងក្រោយពីនេះ
- យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ
- យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនសមធមិការងារ និង គុណសម្បត្តិភាគ២ (រាជរដ្ឋាភិបាលកម្ពុជា ២០០៨)
- ច្បាប់វិមជ្ឈការ និងសហវិមជ្ឈការ
- ហើយនិងផែនការសកម្មភាពអភិបាលកិច្ច ។

គោលនយោបាយក្នុងស្ថានភាពបច្ចុប្បន្ននេះផ្តល់នូវចំណុចចាប់ផ្តើមសំរាប់កម្មវិធីព្រៃឈើជាតិសព្វថ្ងៃ ។

## ២.៣ កាតព្វកិច្ចអន្តរជាតិ

ដោយបន្ថែមទៅលើគោលនយោបាយជាតិ ការគ្រប់គ្រងព្រៃឈើគឺមានកាតព្វកិច្ចដែលត្រូវអនុវត្តតាមអនុសញ្ញាអន្តរជាតិ និងពិធីការដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើសច្ចានុមតិរួចដូចជា :

- វេទិកាអង្គការសហប្រជាជាតិស្តីពីព្រៃឈើ-តាមរយៈនៃការព្រមព្រៀងរបស់គោលការណ៍កម្មវិធីព្រៃឈើជាតិ ។

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីគំរោងការនៃការប្រែប្រួលអាកាសធាតុ ហើយនិងពិធីការក្យូតូ ដែលទាក់ទងទៅនិងព្រៃឈើ ហើយនិងកាបោន ។
- អនុសញ្ញាអន្តរជាតិស្តីពីការប្រយុទ្ធប្រឆាំងភាពរហោដ្ឋាន ។
- អនុសញ្ញាស្តីពីជីវចម្រុះត្រូវបានបង្កើតឡើងក្នុងរង្វង់យុទ្ធសាស្ត្រជាតិជីវចម្រុះ ហើយនិងផែនការសកម្មភាព ឆ្នាំ ២០០២ ។
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងភាពរហោដ្ឋាន ។
- អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិក្នុងប្រភេទរងគ្រោះថ្នាក់នៃពពួកសត្វព្រៃ និងពពួកភូតគាម ។
- អនុសញ្ញាស្តីពីដីសើមដែលមានសារសំខាន់ជាអន្តរជាតិ-អនុសញ្ញា RAMSAR ។
- អនុសញ្ញាទាក់ទងទៅនឹងការការពារវប្បធម៌ពិភពលោក និងមរតកធម្មជាតិ ។
- អនុសញ្ញាអន្តរជាតិចំពោះការការពារបំបាត់ជាតិពុលនៅកន្លែងចាក់សំរាម ហើយនិងវត្ថុធាតុផ្សេងៗទៀត ។
- កិច្ចព្រមព្រៀងអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គម និងសិទ្ធិវប្បធម៌ ។
- កិច្ចព្រមព្រៀងអន្តរជាតិអំពីសិទ្ធិស៊ីវិល និងនយោបាយ ។
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់រូបភាពនូវការរើសអើងពូជសាស្ត្រ ។

កម្ពុជាបានសន្យាចំពោះកិច្ចព្រមព្រៀងក្នុងរង្វង់តំបន់ និងអន្តរជាតិរួមមាន :

- o កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការចំពោះការអភិវឌ្ឍន៍អោយមាននិរន្តរភាពនៅអាងទន្លេមេគង្គ ។
- o អាស៊ាន និង ផែនការសកម្មភាពយុទ្ធសាស្ត្ររៀបចំដោយរៀមច្បងអំពីព្រៃឈើ ហើយនិងផែនការសកម្មភាពជីវចម្រុះតំបន់ ។
- o អង្គការអន្តរជាតិព្រៃឈើតំបន់ក្តៅ ។

## ២.៤ បញ្ហាប្រឈមធំៗក្នុងការគ្រប់គ្រងព្រៃឈើ

តាមពិតទៅការគ្រប់គ្រងព្រៃឈើកម្ពុជា ស្ថិតក្នុងសភាពមិនទាន់រឹងមាំនៅឡើយ ។ ផល និង វត្ថុមួយចំនួនដែលមានតម្លៃ ក៏ដូចជាផលកំរៃសេដ្ឋកិច្ចត្រូវបានគេប្រមូលយ៉ាងសម្បើម ។ ប្រជាជនតាមភូមិប្រមូលអនុផលព្រៃឈើ ហើយនិងឈើ ផ្នែករាជការប្រមូលផល និងរដ្ឋាភិបាលប្រមូលយកកម្រៃពីកិច្ចសន្យានានា ។ បញ្ហាទាំងនេះបានកើតឡើងជាច្រើនដោយខ្វះការយកចិត្តទុកដាក់ដល់ការប្រើប្រាស់ព្រៃឈើទៅអនាគត ។ ដូច្នេះ ការរៀបចំគ្រប់គ្រងសមស្របដោយនិរន្តរភាពជួបប្រទះនូវបញ្ហាប្រឈមដែលមានស្រទាប់ឧបសគ្គជាច្រើន ។

ក្នុងបរិបទនៃស្ថាប័នមានភាពប្រឈមជាច្រើនដែលលេចឡើង :

អភិបាលកិច្ចព្រៃឈើល្អប្រជែងជាពិសេសជាមួយអាជីវកម្មកាប់ឈើល្មើសច្បាប់ ឬការដណ្តើមយកដីដែលធ្វើអោយទីភ្នាក់ងារព្រៃឈើនៃរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពុំមានអំណាចឃាត់ឃាំងឡើយ ។ ប្រហាក់ប្រហែលរឿងនេះដែរ ដីសម្បទានសេដកិច្ចត្រូវបានផ្តល់ដោយពុំមានផែនការច្បាស់លាស់ខ្វះការពិគ្រោះយោបល់ ឬការការពារផលប្រយោជន៍របស់អ្នកមួយចំនួននៅទីកន្លែងមូលដ្ឋាន ។ ក្រុមអ្នកវិនិយោគអាចមានអំណាចដែលភ្នាក់ងារគ្រប់គ្រងព្រៃឈើពុំហ៊ានអនុវត្តនូវនីតិក្រម និងការគ្រប់គ្រងតាមច្បាប់បានឡើយ ។ រាជរដ្ឋាភិបាលកន្លងមកបានប្រកាសថាជាអំពើល្មើសច្បាប់ចំពោះ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចដោយអភិបាលខេត្ត។

- មានការខ្វះខាតច្រើនក្នុងការរៀបចំផែនការអន្តរស្ថាប័ន លើការគ្រប់គ្រងព្រៃឈើ និង ដីព្រៃ ។ សេចក្តីសម្រេចមួយចំនួនលើការប្រើប្រាស់ដីព្រៃអាចអាចត្រូវបានធ្វើឡើងដោយអ្នកខាងក្រៅ ពិសេសក្នុងករណីចំពោះសម្បទានសេដ្ឋកិច្ចដីអភិវឌ្ឍន៏ ហើយនិងដីផ្លូវថ្នល់ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត (ឧទាហរណ៍ ការស្ថាបនាវ៉ារីអគ្គីសនី) ។

- សមត្ថភាពក្នុងការរៀបចំ និងគ្រប់គ្រងគម្រោង ឬការវិនិយោគមិនទាន់មានគ្រប់គ្រាន់នាំឱ្យខ្វះលទ្ធភាពរារាំង ការពារ ហើយជួនកាលនាំឱ្យមានការជជែកមិនច្បាស់លាស់ ។ ចំពោះសកម្មភាពទាក់ទង និងអាកាសធាតុលទ្ធភាព និងបទពិសោធន៏ក្នុងការរៀបចំគម្រោងការត្រួតពិនិត្រគម្រោង និងការពិភាក្សាលើកិច្ចសន្យាស្ទើរតែគ្មាន ។

- ប្រព័ន្ធផ្សព្វផ្សាយព្រៃឈើ និងតំបន់ការពារព្រៃឈើនៅខ្វះបុគ្គលិកមិនអាចត្រួតពិនិត្យលើទំហំដីធំបាន ហើយនិងខ្វះមធ្យោបាយខ្វះចំណេះដឹងអំពីការគ្រប់គ្រងព្រៃឈើដោយនិរន្តភាពទីផ្សារ ឬសិទ្ធិក្នុងមូលដ្ឋាន ។

- សមត្ថភាពសហគមន៏មូលដ្ឋានដើមសម្រាប់ការអនុវត្តន៏ ការស្រាវជ្រាវអំពីព្រៃឈើមិនទាន់មានគ្រប់គ្រាន់ក្នុងចំណេះដឹងតិចតួចសម្រាប់គាំទ្រដល់ការអនុវត្តន៏លើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

- សម្បត្តិព្រៃឈើមិនទាន់កំណត់ព្រំប្រទល់ច្បាស់លាស់ក្នុងរង្វង់សម្បត្តិព្រៃឈើអចិន្ត្រៃយ៏ ការចាត់ថ្នាក់ព្រៃឈើ ហើយការប្រើប្រាស់នៅខ្វះចន្លោះ។

- មូលដ្ឋានពតិមានដែលមានស្រាប់អំពីព្រៃឈើនៅមិនទាន់គ្រប់គ្រាន់ មិនច្បាស់លាស់ហើយទិន្នន័យមិនបានផ្គត់ផ្គង់គ្រប់គ្រាន់ចំពោះឧទាហរណ៏ ការរៀបចំការអនុវត្តន៏យុទ្ធសាស្រ្តគ្រប់គ្រង ឬការធ្វើអន្តរកម្មជាមួយអ្នកវិនិយោគបរទេសទៅផលិតផលឈើ ឬកាបោន ។

ការអោយតម្លៃផ្នែកសេដ្ឋកិច្ចការគ្រប់គ្រងព្រៃឈើនៅមិនទាន់ត្រូវបានគេយកចិត្តទុកដាក់នៅឡើយទេ ។ គេឃើញមានការផ្តល់វាយតម្លៃតិចតួចអំពីតំបន់ព្រៃឈើ ឬអំពីតម្លៃ និង សេវ៉ាដែលផ្តល់ដោយព្រៃឈើ។ នេះជាមូលហេតុដែលថាហេតុអ្វីបានជាព្រៃសម្បទានត្រូវបានផ្តល់ដើម្បីទទួលផលក្នុងរយៈពេលមួយខ្លី រីឯការខូចខាតសម្រាប់រយៈពេលមួយយូរអង្វែងនៅមិនទាន់ស្វែងយល់ ឬក៏មិនទាន់បានគិតដល់ ។

តំលៃវប្បធមិ សង្គម និង បរិស្ថានជាញឹកញាប់មិនត្រូវគេយកចិត្តទុកដាក់ទេក្នុងការគ្រប់គ្រងព្រៃឈើ និងដីព្រៃ ។

ជាលទ្ធផលការគ្រប់គ្រងព្រៃឈើមកដល់ពេលនេះគ្រាន់តែជាជម្រើសតូចតាច ហើយមិនសូវស៊ីសង្វាក់ជាមួយច្បាប់ និងអនុសញ្ញាអន្តរជាតិខ្លះផងដែរ ។

## ២.៥. ដី និង ព្រៃឈើ : ការប្រជែងជាក់លាក់មួយចំពោះព្រៃឈើកម្ពុជា

ការទន្ទ្រានយកដីបែបអាណាធិបតេយ្យនៅតំបន់ព្រៃ រួមទាំងតំបន់ការពារទទួលការរីករាលដាលធំឡើងៗសម្រាប់ពង្រីកទីក្រុង និងបូរីនានា និង ទីកន្លែងផ្សេងទៀតដែលមានកំណើនប្រជាជនរស់នៅជិតព្រៃកាន់តែច្រើន និងដីសម្បទានសេដ្ឋកិច្ចត្រូវបានផ្តល់ថែមទៀត (អនុក្រិត ២០០៥) ដែលធ្វើអោយការប្រើប្រាស់ដីព្រៃសម្រាប់ប្រកបរបរកសិកម្មកាន់តែរីកធំផងដែរ ។

ដីសម្បទានសេដ្ឋកិច្ច ត្រូវបានផ្តល់ឱ្យនៅលើផ្ទៃដីមានដីមានព្រៃ និងអតីតព្រៃសម្បទានដែលផ្ទុយពីច្បាប់ស្តីអំពីព្រៃឈើ ។ ជាលទ្ធផលការកាប់ឆ្ការព្រៃទំហំធំធេងបណ្តាលអោយមានផលប៉ះពាល់អវិជ្ជមានដល់វិស័យព្រៃឈើ និងជីវិតរស់នៅរបស់ប្រជាជនមូលដ្ឋាន ហើយនិងបង្ហាញឱ្យឃើញនូវគ្រោះមហន្តរាយដែលបណ្តាលមកពីការខ្វះការធ្វើសមាហរណកម្មផែនការវិស័យផ្សេងទៀត និងកង្វះខាតក្នុងការអនុវត្តច្បាប់ ។ ការអនុញ្ញាតឱ្យដីសម្បទានសេដ្ឋកិច្ចជាធម្មតាអនុលោមតាមអនុក្រឹត្យសម្រាប់គោលបំណងនេះ ដែលតំរូវអោយមានការវិភាគលើការប៉ះពាល់បរិស្ថាន ហើយនឹងសង្គម ក៏ដូចជាត្រូវការពិគ្រោះយោបល់សាធារណៈ ព្រមទាំងឱ្យមានការគោរពបទបញ្ញាមួយចំនួនស្តីអំពីការប្រើប្រាស់ដីធ្លី និងសិទ្ធអ្នកប្រើប្រាស់ ។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងមានការបំពានដល់គោលការណ៍នៃអភិបាលកិច្ចល្អដោយមិនបានពិគ្រោះយោបល់ គ្រាន់តែមានជានាមថាពិគ្រោះយោបល់ចំពោះវិស័យសំខាន់ផ្សេងៗទៀត និងខ្វះការយកចិត្តទុកដាក់ចំពោះផែនការអន្តរវិស័យ និង ផលប្រយោជន៍ សេដ្ឋកិច្ច សង្គម វប្បធម៌ និង បរិស្ថាន ។

ក្នុងចំណោមផលប៉ះពាល់អវិជ្ជមានចំពោះជីវិតរស់នៅតាមមូលដ្ឋានគឺការបាត់បង់ដីព្រៃ ការខាតបង់ពីការរកបានអនុផលព្រៃឈើ ការខាតបង់យ៉ាងធំនូវតំបន់ព្រៃសក្ការៈរបស់ប្រជាជន ការផ្លាស់ប្តូរទីកន្លែង របស់ប្រជាជន និងការផ្លាស់ប្តូរលំនៅដ្ឋាន ក៏ដូចជាការបំផ្លិចបំផ្លាញបរិស្ថាន ។ ការធ្វើសម្បទានសេដ្ឋកិច្ច (និង ដីសម្បទានផ្សេងៗដូចដីជីកយករ៉ែ) មានឥទ្ធិពលលើសហគមន៍ជនជាតិដើមភាគតិចជាអវិជ្ជមាន ។ ឥទ្ធិពលបែបនេះធ្វើឱ្យអន្តរាយដល់ជីវិតរស់នៅ និងលទ្ធភាពចុះបញ្ជីកាកម្មសិទ្ធនៃដីប្រពៃណីរបស់ពួកគាត់ ។ មានដីសម្បទានមួយចំនួនត្រូវបានលុបចោលដោយរាជរដ្ឋាភិបាលកម្ពុជា ដោយសារក្រុមហ៊ុនមិនអនុលោមតាមកិច្ចសន្យា ។ ជាជំនួយដីព្រៃមួយចំនួនត្រូវបានផ្តល់ឱ្យសហគមន៍ដូចជាសហគមន៍ព្រៃឈើ ឬផ្តល់ក្រោមរូបភាពផ្សេងទៀត ។

## ២.៧ . ឈើ និង អនុផលព្រៃឈើ

ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពត្រូវយកចិត្តទុកដាក់ពីរយ៉ាងគឺ **ឈើ** និង **អនុផលព្រៃឈើ** ។ អនុផលព្រៃឈើសំដៅលើរុក្ខជាតិ ឬ ផ្សិត ឬក៏សត្វ ដែលមានតម្លៃសម្រាប់ឱសថ និង អត្ថប្រយោជន៍ផ្សេងទៀត

នៃគុណប្រយោជន៍ពាណិជ្ជកម្ម (ដូចជាជ័រឈើនៅកម្ពុជា) សត្វសម្រាប់ប្រមាញ់ ផ្កាសម្រាប់ធ្វើឱសថ ឬអ្វីផ្សេងៗទៀត ។

បច្ចុប្បន្ននេះ អនុផលព្រៃឈើមួយចំនួនមានសារសំខាន់យ៉ាងខ្លាំងក្នុងយុទ្ធសាស្ត្រជីវិតរស់នៅរបស់ប្រជាជននៅជិតព្រៃ ។ បើសិនខ្វះការយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវតម្លៃសេដ្ឋកិច្ច និងសង្គមនេះត្រូវខាតបង់នៅពេលដែលព្រៃឈើត្រូវប្រែក្លាយព្រៃសម្បទានជារង្វាន់ដែលប្រជាជន ឬប្រជាជនត្រូវខាតបង់ប្រាក់ចំណូលពីព្រៃឈើ។ អាចមានលទ្ធភាពបាត់បង់អនុផលព្រៃឈើពីចំណេះដឹងតិចតួច អំពីការប្រើប្រាស់វាដែលមានកម្រិតឧស្សាហកម្មក្នុងសក្តានុពលធំដោយផ្អែកលើមូលដ្ឋាននៃវិស័យទំនើបក្នុងការប្រើប្រាស់អនុផលព្រៃឈើ នឹងបណ្តាលអោយលក្ខណៈប្រសើរបំផុតរបស់វាត្រូវថយចុះ ។

## ២.៨. ព្រៃឈើ និង វិបត្តិអាកាសធាតុ

វិបត្តិអាកាសធាតុបង្កើតនូវបញ្ហាប្រឈមថ្មីមួយចំពោះព្រៃឈើទូទាំងសកលលោក ប៉ុន្តែវាក៏ជាឱកាសដែរព្រោះព្រៃជាអាងស្តុកកាបោន ហើយថ្មីៗនេះមានការទទួលស្គាល់កាន់តែច្រើននូវតួនាទីរបស់ព្រៃឈើក្នុងការធ្វើឱ្យមានលំនឹងនៃប្រព័ន្ធបរិស្ថាន ។ គម្រោងការដាក់លាក់នៃសកម្មភាពអាកាសធាតុសាកលជាពិសេសពាក់ព័ន្ធជាមួយព្រៃឈើកំពុងវិវត្តន៍យ៉ាងឆាប់រហ័ស ជាមួយគ្នានេះដែរសមត្ថភាពស្ថាប័ន និងយុទ្ធសាស្ត្រជាតិរបស់កម្ពុជាទាក់ទងនឹងបញ្ហានេះ ក៏កំពុងត្រូវបានពង្រឹងពង្រីកបន្ថែម ។

# ៣. ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តចំពោះការគ្រប់គ្រងព្រៃឈើអោយមាននិរន្តរភាព និងចាប់ផ្តើមអនុវត្តកំលាំងមួយចំនួនដើម្បីសំរេចគោលដៅនេះ ។ ការអនុវត្តន៍ជាក់ស្តែងមួយចំនួនដោយបុគ្គលអ្នកមានអំណាច និងឯកជនលើការធ្វើអាជីវកម្មឈើល្មើសច្បាប់ឬការអនុញ្ញាតផ្តល់ដីសម្បទានសេដ្ឋកិច្ចដោយខ្វះការពិគ្រោះយោបល់ត្រឹមត្រូវ ការពិនិត្យ ការធ្វើផែនការ ឬការគ្រប់គ្រងអោយបានត្រឹមត្រូវនៅតែគំរាមកំហែងដល់ការប្តេជ្ញារបស់រាជរដ្ឋាភិបាល ។

**និយមន័យនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដោយអង្គការស្បៀងអាហារ និងកសិកម្ម អង្គការសហប្រជាជាតិ :**

គឺការកាន់កាប់ទ្រព្យសម្បត្តិ និងការប្រើប្រាស់ព្រៃឈើ និងដីព្រៃតាមក៏រិតដែលរក្សានូវជីវៈចំរុះ ផលិតភាពសម្ថភាពនៃការដុះដាលឡើងវិញ ការរស់រាន និងធានានូវសក្តានុពលដើម្បីបំពេញសេចក្តីត្រូវការនៅពេលនេះ និងអនាគតពិសេសតំរូវការបរិស្ថាន សេដ្ឋកិច្ច និងសង្គមនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ ហើយដែលការគ្រប់គ្រងនោះមិនបណ្តាលឱ្យអន្តរាយដល់ប្រព័ន្ធបរិស្ថានផ្សេងៗទៀត ។

កម្មវិធីព្រៃឈើជាតិទទួលស្គាល់នូវនិយមន័យនេះ និងយល់ច្បាស់អំពីការគ្រប់គ្រងដោយនិរន្តរភាពនៅកម្រិតជាតិ និងកំរិតតំបន់ក៏ដូចសមាហរណកម្មនៃគោលការណ៍ទាំងអស់សំរាប់ ធ្វើផែនការ ការគ្រប់គ្រង ការប្រើប្រាស់ព្រៃឈើ :

**ស្ថាប័ន :** អភិបាលកិច្ចល្អនៃព្រៃឈើ និងការធ្វើសេចក្តីសំរេចក្នុងការគ្រប់គ្រងត្រូវរួមបញ្ចូលអ្នកពាក់ព័ន្ធទាំងអស់ ហើយអ្នកគ្រប់គ្រងព្រៃឈើត្រូវមានសមត្ថភាពអនុវត្តប្រកបដោយប្រសិទ្ធិភាព ។ សិទ្ធិស្របច្បាប់របស់អ្នកពាក់ព័ន្ធទាំងអស់ចំពោះព្រៃឈើ ការប្រើប្រាស់និងការទទួលកម្រៃពីព្រៃឈើ និងពីផលិតផលព្រៃឈើត្រូវបានគោរព និងគ្រប់គ្រង ។

**សេដ្ឋកិច្ច :** រាល់ផលចំណូលទាំងអស់ពីទំនិញ ឬផលិតចេញពីព្រៃឈើ និងសេវាព្រៃឈើ ផ្តល់ឱ្យសង្គមត្រូវបានទទួលស្គាល់ និងរក្សាទុក ឬបង្កើនឡើង ហើយនិងសុខភាពនិងគុណភាពរបស់ព្រៃឈើត្រូវបានថែទាំនិងបង្កើនបន្ថែម ។ កម្រៃបានមកពីផលិតផល និងសេវាទាំងនេះត្រូវបែងចែកប្រកបដោយសមធម៌ ។

**សង្គម និង វប្បធម៌ :** រាល់តម្លៃទាំងអស់នៃសង្គម និង វប្បធម៌ព្រៃឈើ សំរាប់ជនជាតិភាគតិច ហើយ និងក្រុមក្នុងសង្គមខុសៗគ្នា ព្រមទាំងអ្នកពាក់ព័ន្ធខុសៗគ្នា ត្រូវបានទទួលស្គាល់ហើយតម្លៃបានមកពីព្រៃឈើទាំងអស់នេះត្រូវតែថែរក្សា ។

**បរិស្ថាន :** ប្រព័ន្ធបរិស្ថាន និងសេវាបរិស្ថានដែលត្រូវបានផ្តល់ដោយព្រៃឈើត្រូវបានថែរក្សាទុក និងទទួលស្គាល់ ហើយជីវៈចម្រុះនៃព្រៃឈើ និងប្រព័ន្ធបរិស្ថាន របស់វាត្រូវបានថែទាំការពារ ។

**តំបន់ទីជម្រាល :** តំបន់ទីជំរាលព្រៃឈើ និងទេសភាពទាំងឡាយដែលពាក់ព័ន្ធនឹងព្រៃឈើត្រូវបានរៀបចំគ្រប់គ្រងដោយផ្អែកលើមូលដ្ឋាននៃមុខងារទីជម្រាល ហើយស្ថិតនៅក្រោមបញ្ញត្តិនៃស្ថាប័ន និងគោលការណ៍បរិស្ថាន ។ ការគ្រប់គ្រងព្រៃឈើកម្ពុជាកន្លងមក មិនសូវបានដើរតាមគោលការណ៍ទាំងនេះនៅឡើយទេ ។

## ៤_កម្មវិធីព្រៃឈើជាតិកម្ពុជា :

គោលបំណងនៃកម្មវិធីព្រៃឈើជាតិ គឺការបង្កើតក្របខ័ណ្ឌនយោបាយសង្គម នយោបាយសម្រាប់ការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ការអភិរក្ស ហើយនិងការអភិវឌ្ឍន៍ព្រៃឈើដោយនិរន្តរភាព ។

**កម្មវិធីព្រៃឈើជាតិកម្ពុជា**

| |
|---|
| ដើម្បីបង្កើត និង កំណត់យន្តការសំរាប់ដំណើរការចូលរួមដើម្បីសំរេចអោយបាននូវក្របខ័ណ្ឌព្រៃឈើប្រកបដោយនិរន្តរភាពសំដៅបំពេញតំរូវការផលិតផល និង សេវាកម្មព្រៃឈើសំរាប់មនុស្សនាពេលបច្ចុប្បន្ន និងតទៅអនាគត ។ |

កម្មវិធីព្រៃឈើជាតិមានគោលបំណងផ្តល់នូវក្របខ័ណ្ឌដ៏ច្បាស់លាស់មួយសំរាប់រៀបចំផែនការ ការអនុវត្តន៏ ការវាយតម្លៃសកម្មភាពព្រៃឈើនៅថ្នាក់មូលដ្ឋាននៅកម្រិតជាតិ និងកម្រិតក្រោមជាតិ ។ ដំណើរការអនុលោមទៅតាមគោលការណ៏នៃអភិបាលកិច្ចល្អ ការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ ហើយកិច្ចសហប្រតិបត្តិការអន្តរវិស័យនៅគ្រប់ដំណាក់កាល ។

កម្មវិធីព្រៃឈើជាតិនេះគឺជាឯកសារគោលក្នុងវិស័យព្រៃឈើដោយមានបញ្ជាក់គោលដៅ បញ្ហាប្រឈម ការងារអាទិភាព និងដំណោះស្រាយ ។ កម្មវិធីផ្តល់ឱ្យអ្នកពាក់ព័ន្ធនូវការយល់ដឹងរួមមួយនៃទិសដៅអភិវឌ្ឍន៏វិស័យព្រៃឈើ និង សុខដុមកម្មរបស់វាជាមួយផែនការអាទិភាពអភិវឌ្ឍន៏របស់ជាតិ ។

## ៤.១.ចក្ខុវិស័យ និងបេសកកម្មនៃព្រៃឈើ និងវនវប្បកម្មកម្ពុជា :

កម្មវិធីព្រៃឈើជាតិនេះនាំបើកទំព័រសករាជថ្មី នៃទិសដៅជាយុទ្ធសាស្រ្តក្នុងវិស័យព្រៃឈើ ។ ចក្ខុវិស័យ និងបេសកកម្មសម្រាប់ព្រៃឈើត្រូវបានបញ្ជាក់ក្នុងសេចក្តីថ្លែងការណ៏របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីនយោបាយវិស័យព្រៃឈើជាតិ ហើយនិងច្បាប់ស្តីពីព្រៃឈើ ។

ចក្ខុវិស័យនេះគឺជាគោលដៅរយៈពេលវែងដែលកំណត់ទិសដៅក្នុងការ ធ្វើផែនការ និងការអនុវត្តន៏ ។ ចក្ខុវិស័យនេះពិពណ៌នាអំពីសេចក្តីប្រាថ្នាចំពោះអនាគតតែមិនបានបញ្ជាក់អំពីមធ្យោបាយដែលនិងត្រូវប្រើប្រាស់សម្រាប់ធ្វើឱ្យបានសម្រេចចុងក្រោយនូវវត្ថុបំណងអនាគតនេះទេ ។

### ចក្ខុវិស័យ

| |
|---|
| ' រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថា ការអភិរក្ស និងការគ្រប់គ្រងធនធានអោយគង់វង្សដែលធានាផលប្រយោជន៏បរិស្ថាន សង្គម និងសេដ្ឋកិច្ច គឺជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់សុខុមាលភាពសាធារណៈរួមវិភាគទានដល់ការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គម ការការពារបរិស្ថាន និង ការកាត់បន្ថយភាពក្រីក្រ " ។ |

សេចក្តីថ្លែងការណ៏នៃបេសកកម្មនេះធ្វើឱ្យឃើញច្បាស់លាស់ នូវទិសដៅ និងគោលបំណងក្នុងវិស័យព្រៃឈើ ។

### បេសកកម្ម

| |
|---|
| ' ធានាការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាពសម្រាប់បម្រើផលប្រយោជន៏ឱ្យសង្គម សេដ្ឋកិច្ច និង បរិស្ថានរួមទាំងការអភិរក្សជីវចម្រុះ ហើយនិងមរតកវប្បធម៌ជាតិ " ។ |

## ៤.២.ការរៀបចំវិធីសាស្រ្តអំពីការបង្កើតរូបមន្តជាក់លាក់ ការប្រតិបត្តិ ការពិនិត្យឡើងវិញទៅលើកម្មវិធីព្រៃឈើជាតិ:

គោលការណ៏នៃម្ចាស់កម្មសិទ្ធជាតិ ភាពជាប់លាប់ក្រោយការធ្វើសមហរណកម្មក្នុងរង្វង់វិស័យព្រៃឈើ និងដៃគូ ហើយនិងការចូលរួមមានសារសំខាន់ណាស់សម្រាប់ជួយដល់ការរៀបចំការបង្កើតមុខងារ ហើយនិងការពិនិត្យ

ឡើងវិញនៃកម្មវិធីព្រៃឈើជាតិ ។ ភាពជាកម្មសិទ្ធិបានបញ្ជាក់ច្បាស់លាស់ក្នុងភាគខ្លះដោយការប្រកាន់ខ្ជាប់ច្បាប់ គោលនយោបាយ និង សេចក្តីថ្លែងការណ៍ក៏ដូចជាអនុសាសន៍អំពីការពិនិត្យឡើងវិញលើព្រៃឈើកន្លងទៅ ។ លើសពីនេះរាជរដ្ឋាភិបាលកម្ពុជាបានធ្វើការដឹកនាំក្នុងការរៀបចំកម្មវិធីព្រៃឈើជាតិ ដោយមានការចូលរួមសម្រប សម្រួលមតិលើគ្រប់វិស័យពាក់ព័ន្ធតាមរយៈនៃការបង្កើតក្រុមការងារ ហើយអនុវត្តនីតិវិធីសាស្ត្រដែលមិនធ្លាប់មាន ពីមុនពិសេសការពិគ្រោះយោបល់ជាសាធារណៈ ។ ការពិគ្រោះយោបល់នេះមានរួមទាំងសហគមន៍មូលដ្ឋាន ហើយ និងអង្គការក្រៅរដ្ឋាភិបាលជាតិជាច្រើន ។ ការអនុវត្តន៍កម្មវិធីព្រៃឈើជាតិត្រូវដើរតាមគន្លងពីមុន តាមរយៈ របាយការណ៍មានតម្លាភាពអំពីភាពរីកចម្រើន និងការអភិវឌ្ឍន៍ក៏ដូចជាការប្រកួតប្រជែង ។ នេះគឺជាគោលបំណង ធំ និងកាតព្វកិច្ចនៃប្រពន្ធ័តាមដាន ក៏ដូចជាភាគមួយនៃការតាមដាន និង សវនាការសាធារណៈអំពីការជឿនលឿន របស់កម្មវិធីព្រៃឈើជាតិនឹងត្រូវធ្វើឡើងក្នុងចន្លោះពេលទៀងទាត់ ។

រាល់៥ឆ្នាំម្តងកម្មវិធីព្រៃឈើជាតិត្រូវកែលំអអោយទាន់សម័យកាលវិធីសាស្ត្រនឹងត្រូវបញ្ចេញគោលគំនិតតាមរយៈ ផ្សព្វផ្សាយរបាយការណ៍អំពីភាពជឿនលឿន ដោយដើរតាមគន្លងនៃការពិគ្រោះយោបល់សាធារណៈដើម្បីរួម បញ្ចូលសហគមន៍មូលដ្ឋានហើយនិងសេចក្តីសម្រេចនានាអោយទាន់សម័យកាល របស់រាជរដ្ឋាភិបាលកម្ពុជា ។ កម្មវិធីព្រៃឈើជាតិនឹងធានាដល់ការទំនុកបម្រុងឯកសារ និងរបាយការណ៍អំពីភាពជឿនលឿន ដែលនឹងមានផ្សព្វ ផ្សាយតាមអ៊ិនធឺណេតជាភាសារខ្មែរ និង អង់គ្លេស ដែលជាសកម្មភាពនៃការតាមដានផ្តល់ទិន្នន័យនិងការវិភាគ ។

## ៥. យុទ្ធសាស្ត្រដឹកនាំ និងវិធានរបស់កម្មវិធីព្រៃឈើជាតិ

ដោយប្រកាន់ខ្ជាប់នូវទិសដៅទាំងអស់ដែលមានចែងក្នុងផែនការអភិវឌ្ឍន៍ជាតិយុទ្ធសាស្ត្រ (២) យុទ្ធសាស្ត្រ ចតុកោណ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ទិសដៅយុទ្ធសាស្ត្រព្រៃឈើកម្ពុជាមាន :

- បង្កើនវិភាគទានបានមកពីព្រៃឈើសម្រាប់ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចទាំងមូល ។
- ក្លាយទៅជាប្រទេសផ្គត់ផ្គង់នាំមុខគេនៅអាស៊ីអាគ្នេយ៍ ខាងឈើគុណភាព និងតម្លៃខ្ពស់ភ្ជាប់ជាមួយ តម្លៃនៃអនុផលព្រៃឈើ ។
- ក្លាយទៅជាប្រទេសផ្គត់ផ្គង់នាំមុខគេនូវទីផ្សារដាច់ពីគេអំពីការបំបាត់ជាតិកាបោនដែលផុសចេញ ។

ធ្វើអោយវិភាគទានកើនឡើងចំពោះសេដ្ឋកិច្ចទាំងមូលតាមរយៈ :

- យុទ្ធសាស្ត្រអភិវឌ្ឍន៍គឺជាផលប្រយោជន៍អាជីវកម្មនៃតម្លៃខ្ពស់នៅទីផ្សារសម្រាប់ផលិតផលឈើ និង ឈើក៏ដូចជាអនុផលព្រៃឈើដែលបានមកកម្រៃ តាមរយៈនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព សេចក្តីបញ្ជាក់ វិញ្ញាបនកម្ម ហើយនិងវិភាគទានសង្គម ។
- បង្កើនប្រាក់ចំណូលស្របច្បាប់ពីសិប្បកម្ម និងឧស្សាហកម្មក្នុងស្រុកដែលមានមូលដ្ឋានមកពីផលិតផល ឈើ អនុផលព្រៃឈើ និងផលព្រៃឈើផ្សេងៗទៀត ។

- ទទួលស្គាល់សេដ្ឋកិច្ចពីសេវាប្រពន្ធ័បរិស្ថានរបស់ព្រៃឈើដែលទាក់ទងជាមួយការផ្គត់ផ្គង់ទឹក ការពារហេដ្ឋារចនាសម្ពន្ធ័ និងភាពដែលប្រែប្រួលទៅតាមអាកាសធាតុ ។ ធានាសុវត្ថិភាពដល់ការទទួលស្គាល់តម្លៃ និងសេវាកម្មព្រៃឈើដែលផ្តល់នូវប្រាក់ចំណូលដោយចំពោះតាមរយៈ ហិរញ្ញវត្ថុ កាបោនអន្តរជាតិ និង ផ្សេងៗ ការចំណាយរបស់ជាតិសម្រាប់សេវាបរិស្ថាន ។ តាមរយៈនៃរបៀបរៀបរយក្នុងសកម្មភាពសេដ្ឋកិច្ច និងតាមរយៈនៃការថែរក្សា និងការប្រតិបត្តិរបស់ប្រជាជនមូលដ្ឋានក្នុងការចូលដល់ព្រៃឈើ និងការប្រើប្រាស់ផលិតផល និងសេវាកម្មព្រៃឈើ កម្រៃដែលបានមកនឹងបែងចែកប្រកបដោយសមធមិ ។

ដោយដើរតាមផ្លូវនេះកម្ពុជានឹងលូតលាស់ដោយឈររឹងប៉ឹងក្នុងតំបន់ ហើយពិតជាក្នុងពិភពលោកផងព្រមទាំងបើកចំហទីផ្សារដែលអាចជួយឱ្យមាននិរន្តរភាពនៃការអភិវឌ្ឍន៏សង្គម និងសេដ្ឋកិច្ចរបស់ប្រទេស ហើយនិងប្រជាជនក្នុងរយៈពេលវែង ។ ម្យ៉ាងវិញទៀតបើសិនជាគ្មានរបៀបរៀបរយវាលដាលកាន់តែធំឡើងសកម្មភាពល្មើសច្បាប់ ឬស្របច្បាប់បន្តិចបន្តួចក្នុងវិស័យព្រៃឈើ និងបន្តធ្វើឱ្យពុំអាចទប់ស្កាត់បាននៅពេលនោះកម្ពុជា និងបាត់បង់ការកោតញញើតនិងការទទួលស្គាល់ពីសំណាក់អន្តរជាតិ ទទ្ធឹមនឹងលទ្ធភាពអាជីវកម្មនៃតម្លៃទីផ្សារខ្ពស់កើនឡើងដែលរត់រកឈើ (ពិសេសឈើដែលបញ្ជាក់) អនុផលព្រៃឈើកែច្នៃ និងការចាប់យកកាបោន ។

**សេចក្តីសម្រេចយុទ្ធសាស្ត្រធំ១ :**

ការស្វែងរកការសម្របសម្រួល និងការប្តេជ្ញាចិត្តចំពោះការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពដែលនាំមុខនូវការជឿនលឿនសង្គម-សេដ្ឋកិច្ច និងភាពលូតលាស់របស់ព្រៃឈើនឹងជំនួសឱ្យការគ្រប់គ្រងគ្មានរបៀបរៀបរយដែលជាហេតុបើកចំហឱ្យមានការរំលោភបណ្តាលឱ្យអ្នកមានទំនាក់ទំនងខ្ពស់ឆាប់ទទួលការមានបាន និងសម្បូណ៏សប្បាយតែម្នាក់ឯង ហើយជាបច្ច័យអាក្រក់នៃការខូចខាតព្រៃឈើ ។

**ដើម្បីធ្វើឱ្យបានសម្រេចនូវសក្តានុពលនៃផលប្រយោជន៏ដំណោះស្រាយនិរន្តរភាពត្រូវធ្វើច្រើនជំហាន :**

**ស្ថាប័ន និងអភិបាលកិច្ច :**

- កម្រិតខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលត្រូវតែបញ្ឈប់ដោយប្រសិទ្ធិភាពនូវអ្វីដែលគ្មានរបៀបរៀបរយអំពីដីសម្បទានសេដ្ឋកិច្ច ហើយធានាផែនការមួយសមស្របពតិមានអំពីផែនការ ហើយនិងគម្រោងការស្របច្បាប់ចំពោះសម្បទាន ចំពោះសាធារណៈ និងការពិគ្រោះយោបល់ជាសាធារណៈដើម្បីបញ្ចូលសហគមន៏ ការធានាសុវត្ថិភាព និងការគ្រប់គ្រង ហើយនិងវិធីសាស្ត្រនៃការពិនិត្យឡើងវិញអំពីដីសម្បទានសេដ្ឋកិច្ចសព្វថ្ងៃ និងមានលទ្ធភាពចេញឱ្យថ្មី ។ បញ្ហានេះរួមមាន :

- បញ្ឈប់ការលក់ និងការចុះបញ្ជិការដី ហើយនិងការផ្តល់ដីសម្បទានសេដ្ឋកិច្ច ឫសម្បទានផ្សេងៗទៅលើដីព្រៃ និងដីនៅតំបន់ព្រៃការពារ ។

- ការពារសិទ្ធិប្រពៃណីរបស់អ្នកប្រើប្រាស់ក្នុងរង្វង់ប្រភេទដីសម្បទាន ។

• ក៏ដូចជាភាគមួយនៃការកំណត់ព្រំប្រទល់ការផ្តល់កិច្ចសង្គ្រោះដល់ជនជាតិ ហើយនិងសហគមន៍រស់នៅផ្សេងៗទៀតដើម្បីកំណត់ព្រំប្រទល់ដីប្រពៃណីរបស់ពួកកាត់ និងផ្តល់នូវការទទួលស្គាល់ដំបូងទៅលើដីនេះ ការចុះបញ្ជីការធ្វើនៅពេលក្រោយ ។

• ការកំណត់ព្រំប្រទល់រូបវន្តច្បាស់លាស់ និងការគ្រប់គ្រងឱ្យបានណែនលើសម្បទានដែលមានស្រាប់ និងទៅអនាគតដោយភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍អំពីការអនុវត្តន៍សម្បទានដែលជាភាគមួយនៃកម្មវិធីព្រៃឈើជាតិ នៃប្រពន្ធ័តាមដាន ហើយនិងរបាយការណ៍ ។

• កម្រិតដូចគ្នានេះនឹងផ្តល់អំណាចជាក់លាក់ និងពិតៗដល់ការគ្រប់គ្រងព្រៃឈើ(រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន) ដើម្បីបញ្ឈប់ការកាប់ឈើដោយល្មើសច្បាប់ទោះជាមានថ្នាក់ខ្ពស់ណាក៏ដោយ ហើយធានាថាការផ្អាកកាប់ឈើត្រូវប្រតិបត្តិ ។

• ការផ្គត់ផ្គង់ដល់ទីផ្សារក្នុងស្រុកនូវប្រភេទឈើខ្លឹមមានគុណភាពខ្ពស់នឹងត្រូវបានធានាដោយតម្លៃស្របច្បាប់ដូចជានៅតាមសហគមន៍ព្រៃឈើ ឬក៏ ចំការឈើនាអនាគត និងកាត់បន្ថយផលប៉ះពាល់ ពីការកាប់ឈើ និងការគ្រប់គ្រងស្របតាមគោលការណ៍នៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

• មិនដឹងច្បាស់ ប៉ុន្តែអាចសន្មតបានថាបរិមាណដ៏ធំនៃឈើខ្លឹមដែលលក់ឱ្យអតិថិជននៃប្រទេសជិតខាងទោះជាការផ្អាកកាប់ឈើជាទូទៅក៏ដោយ ។ រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការជាមួយរដ្ឋាភិបាលវៀតណាម ថៃឡង់ដ៍ និងសាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវដូចជាប្រជាជាតិអាស៊ាន ដើម្បីធានាឱ្យមានការគោរពរបស់ប្រទេសជិតខាងក្នុងការជួយពង្រឹងដល់ការផ្អាកកាប់ឈើនៅកម្ពុជា ។ ដៃគូអភិវឌ្ឍន៍និងជួយឱ្យមានការគោរពបែបនេះតាមយេៈនៃស្ថានដំណាងក្នុងប្រទេសជិតខាងទាំងនោះ ។

• ប្រទេសកម្ពុជា នឹងពង្រីកហើយនិងអនុវត្តដោយយន្តការបច្ចុប្បន្នហើយកំណត់អត្តសញ្ញាណនៃការខ្វះចន្លោះនៃគម្រោងការទូទៅមួយអំពីប្រតិបត្តិការច្បាប់ស្តីពីព្រៃឈើ ហើយនិងអភិបាលកិច្ចនៃកម្មវិធីព្រៃឈើជាតិ (កម្មវិធីទី៣) ។

• រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើឱ្យបានចម្រើនឡើងព្រមគ្នានូវកិច្ចសហការអន្តរ-ទីភ្នាក់ងារនិងអន្តរក្រសួង ហើយនិងផែនការអំពីធនធានធម្មជាតិព្រមទាំងពង្រីកឧបករណ៍សម្រាប់មូលដ្ឋានផែនការទេសភាព និងការគ្រប់គ្រងធនធានធម្មជាតិ ។ កិច្ចសហការនេះនឹងមានរួមទាំងកិច្ចសហការអន្តរ-ខេត្ត អន្តរ-ស្រុក ក៏ដូចជាឧបករណ៍ និងនិតិក្រមអន្តរ-ភ្នាក់ងាររបស់ពួកគាត់ ។

• អាជ្ញាធរព្រៃឈើ និងអាជ្ញាធរបរិស្ថានទទួលខុសត្រូវចំពោះព្រៃឈើ និងធ្វើអន្តរកម្មយ៉ាងសកម្មមុនគេជាមួយទីភ្នាក់ងារទទួលខុសត្រូវចំពោះហេដ្ឋារចនាសម្ពន្ធ័ (ផ្លូវថ្នល់, ប្រឡាយទឹកឧស្សាហកម្ម, ទីស្នាក់ការស៊ុំចត, កន្លែងជីកយករ៉ែ ) ឧស្សាហកម្ម ថាមពល ការអភិវឌ្ឍន៍ទីក្រុង និងដីសម្បទានសេដ្ឋកិច្ច ដើម្បី សាកល្បងនិតិក្រមពិគ្រោះភ្ជាប់ជាមួយឧបករណ៍ធ្វើផែនការ និងនីតិក្រមនៃសេចក្តីសម្រេចដែលទាក់ទាញសាធារណៈជន ។ អាជ្ញាធរ

ទាំងអស់នេះនឹងធ្វើឱ្យមានរូបរាងឡើងនូវគោលការណ៍ដឹកនាំ និងបទបញ្ញត្តិអំពីការប្រើប្រាស់ដីព្រៃ ឬដីស្ថិតជាប់ព្រៃ ឬដីដែលពុំមានបំណងដាំព្រៃឈើ ហើយនិងដីប្រើប្រាស់សម្រាប់ព្រៃឈើផ្គត់ផ្គង់ឧស្សាហកម្ម ឬសម្រាប់ផលិតថាមពល ។

- អាជ្ញាធរព្រៃឈើ និងអាជ្ញាធរបរិស្ថានទទួលខុសត្រូវចំពោះព្រៃឈើទាមទារឱ្យមានការចូលរួមក្នុងផែនការអំពីការប្រើប្រាស់ និងការចែកចាយទឹកសម្រាប់កសិកម្ម ឧស្សាហកម្ម និងទឹកសម្រាប់ប្រើប្រាស់ក្នុងផ្ទះសម្បែង ។
- រាជរដ្ឋាភិបាលកម្ពុជាតាំងចិត្តថានឹងពង្រីក និងអនុវត្តកម្មវិធីកសាងសមត្ថភាពរួមសម្រាប់បម្រើឱ្យការគ្រប់គ្រងដោយនិរន្តរភាព ដែលជាវិភាគទានមួយយ៉ាងធំក្នុងការកសាងសមត្ថភាពរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ កម្មវិធីនេះនឹងផ្តោតទៅលើប្រពន្ធ័ជួយដល់ការអនុវត្តន៍បទបញ្ញា និងការជំរុញឱ្យស្ថាប័នអនុវត្តក៏ដូចជាអំពីស្ថាប័នទាំងនេះខ្លួនឯងផងដែរកម្មវិធីព្រៃឈើជាតិ (កម្មវិធីទី៥) ។
- រាជរដ្ឋាភិបាលកម្ពុជានឹងកសាងសមត្ថភាពស្ថាប័ន ដើម្បីធ្វើទំនាក់ទំនងទិដ្ឋភាពផ្សេងៗពីគ្នាអំពីវិបត្តិអាកាសធាតុ ហើយនិងឥទ្ធិពលរបស់វាទៅលើ វិស័យព្រៃឈើ ។
- ការធ្វើវិភាជន៍ និងការកំណត់ព្រំប្រទល់ដីព្រៃត្រូវព្យាយាមធ្វើ ហើយនិងការផ្តល់កម្មសិទ្ធិ ។ នីតិវិធីនៃការផ្តល់កម្មសិទ្ធិដល់ជនជាតិកាន់កាប់ដីព្រៃនឹងត្រូវពន្លឿន (កម្មវិធីព្រៃឈើជាតិ កម្មវិធីទី១) ។ ចំពោះបញ្ហាផ្ទៃក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវញែកឱ្យច្បាស់រវាងដីសម្រាប់កសិកម្ម និងដីព្រៃ ។
- បទបញ្ញត្តិនានារបស់សហគមន៍ព្រៃឈើនឹងត្រូវធ្វើការពិនិត្យឡើងវិញតាមលំនាំបទពិសោធន៍កន្លងមកហើយ និងចុះបញ្ជីការសហគមន៍ព្រៃឈើទាំងអស់ (កម្មវិធីព្រៃឈើជាតិ កម្មវិធីទី៤) ។
- រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថា ការអភិវឌ្ឍន៍អំពីការពង្រីកផ្ទៃដីទាក់ទិនព្រៃឈើត្រូវផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ដែលចងក្រងបានមកពីកម្មវិធីព្រៃឈើជាតិ ។ ដើម្បីសក្តានុពលសហគមន៍ព្រៃឈើអាចអភិវឌ្ឍន៍ (ជាភាគ) ឱ្យមានស្វ័យ័តភាពហិរញ្ញវត្ថុ និងយន្តការពង្រីកស្វ័យ័តភាពគ្រប់គ្រង ហើយសម្បទានិកអាចព្យាយាមពង្រីកតាមទម្រង់ផ្សេងៗ ។

**សេដ្ឋកិច្ច :**

ការយកចិត្តទុកដាក់ និងការវាយតម្លៃទៅលើសេដ្ឋកិច្ចត្រូវរួមបញ្ចូលទៅក្នុងនីតិក្រមអន្តរស្ថាប័នដែលបានពិពណ៌នាខាងលើ។ រយៈពេលខ្លីនៃតម្លៃឈើ ឬ តម្លៃកសិផលនៅលើដីព្រៃឈើព្រៃលិចទឹកដែលមានវារីអគ្គិសនី ឬព្រៃត្រូវកាប់ដើម្បីស្តាបនាផ្លូវថ្នល់ត្រូវតែរក្សាតុល្យភាពទប់ទល់នូវ ការបាត់បង់ទឹក ការត្រួតពិនិត្យលើការហូរច្រោះ ជីវចម្រុះ អនុផលព្រៃឈើ សក្តានុពលនៃប្រាក់ចំណូលពីការចាប់យកកាបោនជាដើម ។ ក្នុងនោះផងដែរនៅមានការវាយតម្លៃសេដ្ឋកិច្ចអំពីហេតុបច្ច័យដែលខ្វះនូវសេចក្តីគោរពជាអន្តរជាតិ ធ្វើតាមការបំផ្លាញយ៉ាងបំពាន

ចំពោះធនធានធម្មជាតិ ក៏ដូចជាការបង្កលទ្ធភាពឱ្យមានការបាត់បង់តម្លៃសេដ្ឋកិច្ចជាតិ ឱកាសនៅទីផ្សារអន្តរជាតិ ដូចជាទីផ្សារកាបោន ឬក៏ទីផ្សារឈើវិញ្ញាបនកម្ម ។

- ការគ្រប់គ្រងព្រៃឈើត្រូវមានការបែងចែកដោយសមធម៌អំពីផលប្រយោជន៍ដែលកើតមកពីព្រៃឈើ ដើម្បីធានាដល់ជីវភាពរស់នៅនៃប្រជាជនរស់នៅចំណុះព្រៃឈើ (ប្រជាជនជនបទកម្ពុជាភាគច្រើន) ជីវិតរស់នៅរបស់ប្រជាជនក្នុងការកាប់ឈើផ្គត់ផ្គង់ឱ្យឧស្សាហកម្ម និងវត្ថុផ្សេងៗពីឧស្សាហកម្ម ។
- បច្ចុប្បន្ននេះរដ្ឋ និងសង្គមកម្ពុជាត្រូវធានានូវចំណូលគ្រប់គ្រាន់ពីសកម្មភាពព្រៃឈើក្នុងនាមនៃការបង់តម្លៃសិទ្ធិបង់ពន្ធ ការហូតពន្ធជាដើមក្នុងកម្រិតដែលធ្វើឱ្យសហគ្រាសអាចរស់ទៅបាន ។ ម៉្យាងវិញទៀតរដ្ឋត្រូវការវិនិយោគធនធានក្នុងសេចក្តីត្រូវការធ្វើនិយ័ត្តកម្មការងារក្នុងការប្រតិបត្តិ ហើយនិង តំបន់ផ្សេងៗទៀត ។
- គោលការណ៍ទាំងអស់នេះគឺជាផ្នែកទាំងមូលនៃផលប្រយោជន៍សេដ្ឋកិច្ចព្រៃឈើនីមួយៗអាចជាព្រៃសម្បទានការសម្រុះសម្រួលផ្សេងៗអំពីការកាប់ឈើ ការផ្តល់បទបញ្ជាឱ្យចូល និងប្រើប្រាស់លទ្ធភាពនៃការប្រព្រឹត្តរបស់សហគ្រាសរដ្ឋក្នុងការធ្វើអាជីវកម្មអនុផលព្រៃឈើជាដើម ។
- រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈអភិវឌ្ឍន៍ និងអនុវត្តន៍ផែនការហិរញ្ញវត្ថុសម្រាប់គ្រប់ទិដ្ឋភាពនៃកម្មវិធីព្រៃឈើជាតិនេះ (កម្មវិធីទី៦) ។ ផែនការនឹងរាប់បញ្ចូលលទ្ធភាពនៃប្រភពប្រាក់ចំណូល និងប្រាក់ផ្តល់មកឱ្យក៏ដូចជាគោលការណ៍ណែនាំចំពោះលំហូរហិរញ្ញវត្ថុពីការគ្រប់គ្រងព្រៃឈើដល់ប្រជាជនកម្ពុជា ហើយនិងរដ្ឋាភិបាល។

**ការយកចិត្តទុកដាក់លើបញ្ហាសង្គម វប្បធម៌ និងបរិស្ថាន**

- ការរាប់បញ្ចូលទាំងការពិគ្រោះយោបល់ក្នុងដំណាក់កាលនៃផែនការសម្រាប់ការគ្រប់គ្រងព្រៃឈើ ហើយនិងសម្បទាន ឬក៏ការអភិវឌ្ឍន៍រចនាសម្ព័ន្ធលើដីព្រៃឈើត្រូវការអនុវត្ត ។ ប្រជាជនមូលដ្ឋាននឹងមានផ្លូវថ្មល់ (ហើយកែខៃឡើងវិញនូវយន្តការ) ដើម្បីលើកឡើងនូវទស្សនៈដែលតំណាងឱ្យផលប្រយោជន៍សង្គម និងវប្បធម៌។ អាជ្ញាធរមូលដ្ឋានត្រូវមានអំណាចរួមគ្នាចំពោះគម្រោង ។
- ការគ្រប់គ្រងព្រៃឈើ និងសកម្មភាពផ្សេងៗលើដីព្រៃឈើនឹងក្លាយជាកម្មវត្ថុសម្រាប់បរិស្ថាន ហើយនិងការវាយតម្លៃផលប៉ះពាល់សង្គមត្រូវធ្វើមុននឹងទៅកាន់ប្រតិបត្តិកការនីមួយៗនៃសេចក្តីសម្រេច ។ ការវាយតម្លៃទាំងនេះត្រូវរួមបញ្ចូលទាំងការពិគ្រោះយោបល់សាធារណៈ។
- ការគ្រប់គ្រងព្រៃឈើ និងសកម្មភាពផ្សេងៗលើដីព្រៃគឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញត្រឹមត្រូវ និងស្របច្បាប់មុននឹងចាប់ផ្តើម ។ ការពិនិត្យឡើងវិញនេះ រួមមានកាតព្វកិច្ចរបស់កម្ពុជាចំពោះអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ហើយនិងកិច្ចព្រមព្រៀង ។

គេត្រូវតែធានាអោយបាននូវបទបញ្ជាខាងលើ ដែលមិនរួមបញ្ចូលនូវតម្លៃបន្ថែម និងខ្ពស់ហួសដែលសហគមន៍មូលដ្ឋានមិនអាចទ្រាំបាន ។ បើសិនវាអាចក្លាយទៅជាករណីបែបនេះ បទបញ្ជាខ្លួនឯងដែលមានឆន្ទៈលើកស្ទួយដល់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព នឹងក្លាយទៅជាឧបករណ៍ផ្លាស់លំនៅដ្ឋានប្រជាជនពីដីរបស់ពួកគាត់ ។ នោះ

ជាការលេចឡើងមួយ ប៉ុន្តែវាស្ថិតក្នុងបឋមវិធាននៃប្រព័ន្ធតាមដាន និងការធ្វើរបាយការណ៍អំពីព្រៃឈើគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ (ស្ថិតិព្រៃឈើ) ។ ការគ្រប់គ្រងត្រឹមត្រូវទៅលើព្រៃឈើទាំងអស់ ហើយធានាតម្លាភាពគ្រប់គ្រាន់ដែលជាប្រយោជន៍ដល់មតិសាធារណជាតិ ក៏ដូចជាដៃគូ និង វិនិយោគិនអន្តរជាតិទាមទារប្រព័ន្ធមួយដែលធ្វើអោយការយល់ដឹងបានទូលំទូលាយជាង សក្តិសិទ្ធិជាង ហើយមិនរណបអ្នកគ្រប់គ្រងព្រៃឈើហើយ និងទីភ្នាក់ងារគ្រប់គ្រង ។ ការគ្រប់គ្រងបែបនេះត្រូវតែបានទទួលការទុកចិត្តតាមបែបវិទ្យាសាស្ត្រ ហើយតាមដានរាល់ទិដ្ឋភាពនៃការគ្រប់គ្រងដោយនិរន្តរភាពដែលវាត្រូវតែតភ្ជាប់ត្រង់ទៅនិងការអនុវត្តន៍ច្បាប់ស្តីអំពីព្រៃឈើ ហើយនិង អភិបាលកិច្ច ។ កម្មវិធីព្រៃឈើជាតិនឹងបង្កើតប្រព័ន្ធនេះឡើង ហើយមិនអាចចាត់ទុកជាប្រតិបត្តិការ រួមទាំងយន្តការតម្លាភាពហើយ និងពតិមានផ្តល់មកនៅនឹងកន្លែងរហូតដល់នេះ ។

ប្រព័ន្ធនិងរួមបញ្ចូលបន្ថែម ប៉ុន្តែមិនបានកំណត់ ឬរិតត្បិតចំពោះគុណភាព និងការលូតលាស់នៃព្រៃឈើ ម្ចាស់កម្មសិទ្ធិព្រៃ ការប្រើប្រាស់ព្រៃសម្បទាន (រួមទាំងលក្ខណៈរបស់វាក្នុងនិតិវិធី) ដៃគូអនុវត្តនច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច ។ សកម្មភាពអំពីផែនការកម្មវិធីព្រៃឈើជាតិ ហើយនិងយុទ្ធសាស្ត្រ (លក្ខខណ្ឌ និង លទ្ធភាព) ។

រាជរដ្ឋាភិបាលកម្ពុជាមានសម្បជញ្ញៈល្អដែលធ្វើអោយកើនឡើងនូវសហគមន៍ អន្តរជាតិ ហើយនិងវិនិយោគិនបរទេសទាមទារអោយមានតម្លាភាព និងពតិមានទៀងទាត់ ។ នេះជាភាពជាក់ស្តែងក្នុងការបង្កើនសេចក្តីត្រូវការជាអន្តរជាតិចំពោះវិញ្ញាបនកម្មឈើ ហើយនិងផលិតផលព្រៃឈើផ្សេងៗទៀត វិញ្ញាបនកម្មច្បាប់ដើមនៃផលិតផលខុសៗគ្នា ហើយក្នុងស្ថាប័ន ឬឯកជនដែលផ្តល់មូលនិធិសម្រាប់សំយាក ឬបន្ធូរបន្ថយកាបោនដែលត្រូវព្យាយាមធ្វើក្រោមយន្តការអភិវឌ្ឍន៍ស្អាត ការបញ្ចេញកាបោនថយពីការកាប់ឆ្ការព្រៃ និងការខូចខាតព្រៃ ។ ប្រព័ន្ធនៃការតាមដានចំពោះការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពត្រូវសំអាងលើឯកសារអំពីកម្ពុជា ប្រកាន់ខ្ជាប់នូវការទាមទារ និងគោលការណ៍ទាំងនេះដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

**គោលនយោបាយ ឬលក្ខខណ្ឌប្រកបសំរាប់ការអនុវត្ត ៖**

ក្នុងការអនុវត្តន៍កម្មវិធីព្រៃឈើជាតិ អ្នកពាក់ព័ន្ធអាចយកតាមឯកសារគោលរបស់រាជរដ្ឋាភិបាលដែលគាំទ្រការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ហើយនិងកម្លាំងផ្សេងៗទៀតរបស់កម្មវិធីព្រៃឈើជាតិ ។ យុទ្ធសាស្ត្រចតុកោណដើម្បីការលូតលាស់ ការមានការងារធ្វើ ភាពសមធម៌ និងផលជាទីគាប់ចិត្ត-ដំណាក់កាលទីII ហើយនិងការអនុវត្តន៍គម្រោងការដែលចង្អុលបង្ហាញដូចជាការប្រែប្រួលអាកាសធាតុ និង វិបត្តិសេដ្ឋកិច្ចពិភពលោក ភាពអនាធិតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការទាមទារដីរដ្ឋដោយខុសច្បាស់ និងតំបន់ការពារ ក៏ដូចជាម្ចាស់ដីឯកជនហើយនិងការកាប់ឈើខុសច្បាប់ គុណភាពអប់រំទាប និងកង្វះអ្នកបច្ចេកទេស ។ យុទ្ធសាស្ត្រដាក់ទម្ងន់ទៅលើការផ្តោតចំពោះការពង្រឹងការគ្រប់គ្រងដីការយល់ព្រមជាអាទិភាព ប្រគល់តំបន់ដែលសហគមន៍ជនជាតិរស់នៅដើម្បីកាត់បន្ថយជម្លោះហើយធ្វើផែនទីប្រើប្រាស់ដីធ្លីអោយបានលឿន ។

ដោយភាពច្បាស់លាស់ក្នុងទំនាក់ទំនងការកែទំរង់ព្រៃឈើគឺជាសសរ ឬបង្គោលបីត្រូវបានលិចឡើងដើម្បីធានាដលការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព :

- ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការប្រើប្រាស់ព្រៃឈើដើម្បីអោយការរស់នៅរបស់ប្រជាជនជនបទមានភាពប្រសើរឡើង ហើយវិភាគទានដល់កំណើនសេដ្ឋកិច្ច ។
- ប្រព័ន្ធតំបន់ការពារដើម្បីការពារជីវៈចំរុះ និងប្រភេទងាយរងគ្រោះ ។
- ការបង្កើតកម្មវិធីសហគមន៍ព្រៃឈើ ។

ដូចគ្នានិងយុទ្ធសាស្រ្តចតុកោណផែនការជាតិ យុទ្ធសាស្រ្តអភិវឌ្ឍន៍ កត់សំគាល់បង្គោលបី ចំពោះវិស័យព្រៃឈើ :

- នយោបាយគ្រប់គ្រងព្រៃឈើអោយមាននិរន្តរភាព ។
- ប្រព័ន្ធនៃទំប់ការពារដើម្បីការពារជីវៈចំរុះ និងប្រភេទងាយរងគ្រោះ ។
- ការបង្កើនកម្មវិធីសហគមន៍ជាតិ
- ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ ២០០៦-២០១០

ជាពិសេស ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ បញ្ជាក់ថារាជរដ្ឋាភិបាលសន្យាអនុវត្តន៍កម្មវិធីព្រៃឈើជាតិតាមអាទិភាពដូចតទៅ :

- ផ្តោតទៅលើការកែទម្រង់ព្រៃឈើ ដោយក្រសោបយកនូវ :

១. ពង្រឹកការគ្រប់គ្រងព្រៃឈើ និងការអភិរក្ស ។

២. ផ្សព្វផ្សាយការធ្វើវិភាគទានដល់ការអភិវឌ្ឍន៍ សង្គម និង សេដ្ឋកិច្ច ។

៣. ផ្សព្វផ្សាយការធ្វើវិភាគទានដល់ការកាត់បន្ថយភាពក្រីក្រ ។

៤. ផ្សព្វផ្សាយការដាំឈើដើម្បីជំនួសអោយសេចក្តីត្រូវការ ពីព្រៃឈើជាតិ ។

៥. បង្កើតអោយមានសតិសមជ្ឈញ្ញៈក្នុងការដាំឈើឡើងវិញ និងការប្រើប្រាស់ឈើចំការសហគមន៍ ដើម្បីផលិតអុស និង ធ្យូង ។

ផែនការសកម្មភាពអភិបាលកិច្ច :

អាទិភាពតែមួយគត់ ក្នុងផែនការសកម្មភាពអភិបាលកិច្ច គឺការទទួលស្គាល់ពេញលេញ នូវគោលការណ៍ "អភិបាលកិច្ចល្អគឺប្រសិទ្ធភាព និង តម្លាភាពក្នុងភាពជាដៃគូក្នុងចំណោមអ្នកដែលពាក់ព័ន្ធ" ។

ផែនការសកម្មភាពអភិបាលកិច្ច បញ្ជាក់ប្រាប់ថារដ្ឋាភិបាល និងអនុវត្តន៍សកម្មភាពរបស់គាត់យ៉ាងជាក់លាក់និងមានតម្លាភាពបំផុត និងក្នុងន័យឥតលំអៀង ។

ផែនការសកម្មភាពផ្តោតទៅលើចំណុចសំខាន់៧បី :

១. សមត្ថភាពក្នុងជួរទីភ្នាក់ងារ ដើម្បីធ្វើការសម្របសម្រួល និងការគ្រប់គ្រងមុខងារ ។

២. ធានាពាក្យសន្យារបស់ក្រសួងដែលចេញមកពីក្រសួង ហើយនិងដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការកំណត់អត្តសញ្ញាណសម្ថតភាពដែលត្រូវការពង្រឹក ។

៣. អនុវត្តនកម្មវិធីអភិវឌ្ឍន៍ស្ថាប័ន ។ ក្រុមអនុវត្តន៍ការងារសំរាប់ផែនការបួនឆ្នាំ ក្រសោបយកចំណុចទាំងបីនេះ ។

សារៈសំខាន់របស់កម្មវិធីព្រៃឈើជាតិ មានចំណុចផ្សេងៗទៀត :

- "ប្រេកចូលតាមប្រជាជនគឺជាឧត្តមភាពដើម្បីធានាជីវិតរស់នៅដោយនិរន្តរភាពនិងធូរស្រាលដល់ភាពក្រីក្រ"
- ផ្តោតទៅលើការបង្កើនច្រកចូលស្របច្បាប់ឆ្ពោះទៅ ធនធានធម្មជាតិរបស់ជនក្រីក្រ។
- ភ្ជាប់ការទទួលខុសត្រូវទៅ នឹងតម្រូវការនៃស្ថាប័នអោយដូចៗគ្នា។
- សេចក្តីត្រូវការរបស់គំរោងទាំងស្រុងចំពោះ តំបន់ទាំងអស់។
- ការលើកស្ទួយភាពជាដៃគូ និងតម្លាភាពក្នុងចំណោមអ្នកពាក់ព័ន្ធ។
- ផ្តោតទៅលើការប្រតិបត្តិច្បាប់ និងអនុវត្តន៍ នយោបាយ។
- ផ្តោតទៅលើការ បំបាត់អំពើពុករលួយទាំងស្រុង។

**លក្ខខណ្ឌប្រកប**

ការអភិវឌ្ឍន៍មួយចំនួនក្នុងសង្គមទាំងមូលជះឥទ្ធិពលថាតើហេតុអ្វីបានជាលឿន ហើយហេតុអ្វីបានជាការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងត្រូវបានសំរេច :

ការកែទម្រង់សេវាកម្មស៊ីវិល : រួមទាំងការកែទម្រង់ បៀវវត្សន៍ដូចដែលត្រូវបានត្រួសត្រាយក្នុងវិស័យអប់រំ។

**ការគ្រប់គ្រងដីធ្លី** : ភាពជឿនលឿនទូទៅក្នុងការគ្រប់គ្រងដីធ្លីជាភាគដែលនាំមកនៅភាពច្បាស់លាស់អំពីកម្មសិទ្ធិដីព្រៃ ការកំណត់ព្រំប្រទល់និងការចុះបញ្ជីកា ។ ការគ្រប់គ្រងដីធ្លីនេះអាចត្រូវរំពឹងទុកថា និងមានបញ្ហាព្រំប្រទល់រវាងដីព្រៃនិងដីផ្សេងៗទៀត ។ ដីដែលត្រូវបានដណ្តើមយកនិងត្រូវបានបញ្ឈប់ដើម្បីរក្សាទុកដីឱ្យប្រជាជនមូលដ្ឋាន និងតាមពិតគឺរក្សាគម្របព្រៃឈើឱ្យបានល្អប្រសើរ ។ ការអភិវឌ្ឍន៍វែងឆ្ងាយក្នុងការកែតម្រូវឡើងវិញហើយនិងយន្តការដោះស្រាយទំនាស់ក្រោមការគ្រប់គ្រងដីទូទៅ និងជួយដល់ការអភិវឌ្ឍន៍ទាំងនេះក្នុងរង្វង់ការគ្រប់គ្រងដីព្រៃ ។

**វិមជ្ឈការ និងសហវិមជ្ឈការ :**

កម្មវិធីព្រៃឈើជាតិបច្ចុប្បន្នមានបំណងគាំទ្ររាជរដ្ឋភិបាលក្នុងការខិតខំធ្វើឱ្យបានប្រសើរឡើងនូវការគ្រប់គ្រងវិមជ្ឈការ ។ គោលបំណងនេះគឺបង្កើតឱ្យមានទំនាក់ទំនងល្អរវាងធនធានធម្មជាតិ និងសកម្មភាពគ្រប់គ្រងនៃក្រុមគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន (សង្កាត់ និងស្រុក) ជាមួយសកម្មភាពព្រៃឈើនៃសហវិមជ្ឈការរដ្ឋបាលព្រៃឈើ (ខណ្ឌ និង ផ្នែក) ។ លើសពីនេះ កម្មវិធីព្រៃឈើជាតិមានបំណងបញ្ចូលការគ្រប់គ្រងសហគមន៍ព្រៃឈើប្រពៃណីដែលមានស្រាប់ទៅក្នុងការអភិវឌ្ឍន៍វិស័យព្រៃឈើ ។

វិមជ្ឈការក្នុងវិស័យព្រៃឈើមិនទាន់ចប់ដោយឯកឯងបានទេ ប៉ុន្តែវាជាឧបករណ៍បំពេញឱ្យបេសកកម្មដ៏ធំធេង និង ចក្ខុវិស័យចំពោះការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពហើយ និងការបែងចែកផលប្រយោជន៍ប្រកបដោយគុណធម៌ ។ វិមជ្ឈការនេះផងដែរតាមធម្មជាតិរបស់វាជាប់ទាក់ទងទៅនិងវិធីសាស្ត្រដែលធ្វើឱ្យប្រសើរឡើង

ថែមទៀតនូវអំណាចពន្ធអាករ ហើយនិងឥទ្ធិទៅលើការធ្វើសេចក្តីសម្រេច ។ ការប្រយត្ន័ប្រយែងទៅលើការធ្វើផែនការ ហើយនិងការអនុវត្តន៏ផែនការដោះស្រាយទេសភាពត្រូវតែធានាថា វិមជ្ឈការមិនមែនជាការនាំមុខធ្វើឱ្យបាក់ជាកង់ៗឬធ្វើឱ្យខូចទ្រង់ទ្រាយទេសភាពព្រៃឈើនោះទេ ។ ហេតុដូច្នេះហើយវិធីសាស្រ្តធ្វើឱ្យវិមជ្ឈការ បានជោគជ័យត្រូវព្យាយាមរក្សាតុល្យភាពប្រជាធិតេយ្យនៅមូលដ្ឋានកម្មសិទ្ធព្រៃឈើ ហើយនិងសមត្ថភាព ព្រមទាំងការទទួលខុសត្រូវលើការគ្រប់គ្រង ។

**ការអភិវឌ្ឍន៏ផ្គត់ផ្គង់ថាមពល :**

អុស និង ធ្យូងផ្តល់ឱ្យមួយភាគធំនូវថាមពលសម្រាប់ប្រើប្រាស់ក្នុងផ្ទះសម្បែងនៃប្រជាជនកម្ពុជា និងឧស្សាហកម្មដូចជា ឡឥដ្ឋ-ក្បឿង និងរោងចក្រ សំលៀកបំពាក់មួយចំនួន។ ការកែលំអក្នុងវិស័យផ្គត់ផ្គង់ថាមពលតាមរយៈការប្រើប្រាស់អគ្គិសនី ការប្រើហ្គាសជីវសាស្ត្រនៅតាមតំបន់ជនបទ ហើយនិងវិធី ផ្សេងៗទៀតជាវីភាគទានធ្វើឱ្យប្រសើរឡើងដើម្បីសម្រាលដល់ទម្ងន់ដែលសង្កត់លើព្រៃឈើ ។ កម្មវិធីព្រៃឈើជាតិគាំទ្រការអភិវឌ្ឍន៏បែបនេះ ។

**ការអភិវឌ្ឍន៏វិស័យអប់រំ :**

ការធ្វើឱ្យបានល្អឡើងខាងវិស័យអប់រំទូទៅ និងការអប់រំជាពិសេសទៅលើការគ្រប់គ្រងធនធានធម្មជាតិនឹងនាំមកភាពដែលធ្វើឱ្យប្រសើរ ឡើងចំពោះការអនុវត្តន៏លើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពដោយមន្រ្តីផ្លូវការ ដោយពាណិជ្ជករ និងប្រជាជននៅតាមភូមិ ។

**ប្រព័ន្ធនិរន្តរភាពហិរញ្ញវត្ថុ និងកម្មវិធីវិនិយោគ :**

ការផ្គត់ផ្គង់ហិរញ្ញវត្ថុរយៈពេលវែងជាមួយគោលដៅគាំទ្រការអភិវឌ្ឍន៏ដោយនិរន្តរភាព គឺជាការសម្រេចចំពោះការអនុវត្តលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ពិសេសដំណោះស្រាយបញ្ហាថ្មីៗ និងប្លែកៗ (កម្មវិធីទី៦ពណ៌នារឿងនេះ) ។ ការកែលំអបរិស្ថានសម្រាប់សហគ្រាសខ្នាតតូច និងខ្នាតមធ្យម សហគ្រាសព្រៃឈើដើរទន្ទឹមគ្នាជាមួយសហគ្រាសខ្នាតតូច និងខ្នាតមធ្យមផ្សេងៗទៀតនឹងទទួលបានផលប្រយោជន៏ពីការកែលំអនីមួយៗក្នុងលក្ខខណ្ឌរបស់វា (បទបញ្ជា ផ្គត់ផ្គង់ហិរញ្ញវត្ថុទីផ្សារ ងាយស្រួលជាដើម) ។

**ការចូលដល់-តម្លាភាព-ពតិមានអំពីធនធានព្រៃឈើ :**

ការបើចំហឱ្យចូលដល់ដើម្បីទទួលពតិមានពីធនធានព្រៃឈើហើយនិងការគ្រប់គ្រងរបស់វានិងបណ្តាលឱ្យមានការទុកចិត្តរបស់អ្នកដែលមានបំណងវិនិយោគក្នុងវិស័យព្រៃឈើ ហេតុនេះហើយទើបគេត្រូវធ្វើការវិនិយោគនៅតំបន់ដែលផ្តល់ផលច្រើន ។ កម្មវិធីតាមដានដែលត្រូវពង្រីកក្នុងផ្នែកនៃកម្មវិធីព្រៃឈើជាតិមានគោលបំណងឆ្ពោះទៅរកលក្ខខណ្ឌនេះ ។

ការអនុវត្តន៏កម្មវិធីព្រៃឈើជាតិអាចនឹងទទួលឥទ្ធិពលដោយវិធីសាស្រ្តទាំងអស់នេះ ប៉ុន្តែមិនត្រូវបានប្រកាន់យកក្នុងករណីនៃភាពជឿនលឿនកំពុងចង់បាន ។

### ៥.១ ជម្រើសនៃការគ្រប់គ្រងទៅអនាគត :

ការគ្រប់គ្រងទៅអនាគត នឹងស្វែងរកសុទិដ្ឋិនិយម ក្នុងផ្លូវព្រមព្រៀងមួយអំពីផលប្រយោជន៍សង្គម-សេដ្ឋកិច្ចដែលចេញមកពីព្រៃឈើជាមួយសេវាបរិស្ថាន ដែលហុចផលដោយព្រៃឈើក្រោមការដឹកនាំនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។

**ការកែលំអជីវភាពរស់នៅតាមរយៈ**

- ធ្វើការងារដែលលំអៀងទៅរកព្រៃឈើក្នុងចំការដាំឈើ ហើយនិងព្រៃឈើដែលផ្គត់ផ្គង់ឈើជាមូលដ្ឋានដល់ឧស្សាហកម្ម ( ឈើ, ឈើសម្រាប់កែច្នៃ, អនុផលព្រៃឈើសម្រាប់កែច្នៃ) ។
- ធ្វើការផ្គត់ផ្គង់អាហារ ថ្នាំពេទ្យ ឧបករណ៍ប្រើប្រាស់ចេញមកពីព្រៃឈើ ។
- កម្រៃដល់មូលដ្ឋានបានមកពីវត្ថុធាតុដើមនិងទីផ្សារកាបោន ។

**ចំណូលត្រង់ៗចូលរដ្ឋកើនឡើង ដោយពន្ធអាករ ការបង់ថ្លៃសិទ្ធិ កិច្ចសន្យាក្នុងវិស័យព្រៃឈើមួយយ៉ាងសកម្ម។ ប្រាក់ចំណូលទាំងនេះអាចបានមកពី :**

- ប្រាក់ពន្ធបានមកពីសកម្មភាពពាណិជ្ជកម្ម ។
- ប្រាក់ពន្ធបានមកពីពលករ ។
- ប្រាក់បង់ថ្លៃសិទ្ធិ ពីក្រុមហ៊ុន ឬ សហគមន៍ព្រៃឈើ ។
- ប្រាក់ចុះកិច្ចសន្យា ឧទាហរណ៍ ទាក់ទងការក្សាទុកកាបោន ។

**ចំណូលត្រង់ៗដល់ថវិការដ្ឋកើនឡើង ឬ ការបន្ថយចំណាយតាមរយៈ**

- លះបង់ការប្រើប្រាស់គណនេយ្យសេវាបរិស្ថាន នៃសុខភាពព្រៃឈើ ។
- លះបង់ការប្រើប្រាស់អនុផលព្រៃឈើរបស់ជនជាតិក្នុងតំបន់សុខភាព ។

ក្នុងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ប្រភពសេដ្ឋកិច្ចទាំងនេះនឹងនាំឱ្យមានភាពល្អឡើងពីការជឿនលឿនទូទៅតាមរយៈការបែងចែកដោយសមធម៌ ហើយនិងការចែកចាយជាថ្មីក្នុងរង្វង់ថវិកានៃរដ្ឋាភិបាល ។ ការជ្រើសរើសសម្រាប់គ្រប់គ្រងត្រូវមានការប្រុងប្រយ័ត្នរវាងប្រភេទព្រៃ និងចំណុះលើបញ្ហាដូចជាការចូលដល់ការប្រើប្រាស់ដីព្រៃប្រជែងគ្នា វត្តមានមូលដ្ឋាននៃសហគមន៍ព្រៃឈើ ហើយនិងផ្សេងៗទៀតដែលត្រូវតែរាប់បញ្ចូលក្នុងការអនុវត្តផែនការមូលដ្ឋានទេសភាព ។ ក្នុងការអនុវត្តន៍ដំណោះស្រាយទេសភាពចំពោះការគ្រប់គ្រងព្រៃឈើ និងផែនការមុខងារដែលព្រៃឈើចង់បានគឺជាពិសេសទេសភាពដែលត្រូវបានយកចិត្តទុកដាក់បំផុត ។ ផ្តើមចេញពីទេសភាពនេះជម្រើសគ្រប់គ្រងដែលចង់បាន (ដូចជាសេវាបរិស្ថានធំៗ ផលិតកម្មធំៗ ទៅអនាគត ឬ ការអភិរក្សជីវចម្រុះធំៗ) ដែលត្រូវចាប់យក ។ ក្នុងផែនការនេះការអភិវឌ្ឍន៍ទៅអនាគត (ដូចជាទឹកជំនន់ ភាពរាំងស្ងួត

ការកើនកំដៅ) ដោយមូលហេតុនៃការ ប្រែប្រួលអាកាសធាតុត្រូវតែបានរាប់បញ្ចូលតារាងខាងក្រោមនេះផ្ដល់នូវទស្សនៈលើលទ្ធភាពនៃការជ្រើសរើសដែលកម្មវិធីព្រៃឈើជាតិ កម្មវិធីទី២ អនុកម្មវិធីទី៣ និងបញ្ជាក់ ។

| | ១ | **កម្មសិទ្ធិ និងសិទ្ធិ**<br>**២** | **សិទ្ធគ្រប់គ្រង ទៅអនាគត**<br>**៣** | **ការប្រើប្រាស់តាម អត្ថន័យនិងតាម កាលានុវត្តភាព**<br>**៤** | **ជម្រើសនៃការប្រើ ប្រាស់និងចំណូល**<br>**៥** | **ការ អត្ថាធិប្បាយ**<br>**៦** |
|---|---|---|---|---|---|---|
| **១** | តំបន់ការពារ | រដ្ឋ ការចូលដល់ មួយចំនួន និង ការប្រើប្រាស់ សិទ្ធិ របស់ សហគមន៍ មូលដ្ឋាន | គ្មានការ ប្រែប្រួល | ការអភិរក្ស ជីវចម្រុះ | បរិស្ថានទេសចរណ៍ ប្រាក់ចំណាយលើ សេវាបរិស្ថាន | តំបន់ព្រៃការពារ មួយចំនួនអាចដូរត្រា ទៅវិញទៅមកព្រៃ របស់រដ្ឋបាលព្រៃ ឈើ ។អាចជាផល ប្រយោជន៍ចំពោះ ការការពារក៏ដូចជា ការធ្វើផលិតកម្ម ។ |
| **២** | ព្រៃការពារ | រដ្ឋ ការចូលដល់ និងការប្រើ ប្រាស់សិទ្ធិរបស់ សហគមន៍ មូលដ្ឋាន | សហគមន៍ ព្រៃឈើ ពាណិជ្ជកម្ម មួយចំនួន | ការអភិរក្ស ពន្ធព្រៃឈើ ។ ការការពារដី ជម្រាល ។ ការពារហេ ដ្ឋារចនាសម្ព័ន្ធ ។ អនុផលព្រៃឈើ ។ | បន្ថយការផលប៉ះ ពាល់ដោយការ កាប់ព្រៃឈើ ។ ការប្រមូលអនុផល ព្រៃឈើ ។បរិស្ថាន ទេសចរណ៍ចំណាយ លើសេវាបរិស្ថាន ។ ចាប់យកកាបោន | បន្ថយការប៉ះពាល់ ដោយការកាប់ព្រៃ ឈើក្នុងព្រៃអាច ប្រព្រឹត្តទៅបាន ក្រោមREDDក៏ ដូចជាជីវម៉ាសឈេរ មិនត្រូវកាត់បន្ថយ ។ |
| **៣** | ផលិតកម្មព្រៃ ឈើមិនត្រូវ កាប់រំលីង | រដ្ឋ ការចូលដល់ និងការប្រើ ប្រាស់សិទ្ធិរបស់ | ព្រៃឈើសហគមន៍ ពាណិជ្ជកម្ម ។ ការ កាប់ព្រៃឈើគ្រប់ គ្រងដោយនិរន្តរ | សក្តានុពលកាប់លើព្រៃ គ្រប់គ្រងដោយនិរន្តរ ភាព ។ ការការពារដី ជម្រាល ។ ការការពារ | ការបន្ថយកាបោន REDD ។ ចំណាយលើសេវា បរិស្ថាន ។ | ការដាំឈើ និងការកាប់ឈើ SFMអាចប្រព្រឹត្ត ទៅបាននៅជិតផ្លូវ |

| | | | | | | |
|---|---|---|---|---|---|---|
| | | សហគមន៍មូលដ្ឋាន | ភាពដោយសម្បទាននិកល្បីឈ្មោះទទួលខុសត្រូវ។ | ហេដ្ឋារចនាសម្ព័ន្ធ។ អនុផលព្រៃឈើ។ | | ហើយពលករ។ |
| ៤ | ព្រៃឈើផលិតកម្មបច្ចុប្បន្នកំពុងខូចខាត (ឧទាហរណ៍ ព្រៃសម្បទានកាលពីមុន) | រដ្ឋ ការចូលដល់ និងការប្រើប្រាស់សិទ្ធិរបស់សហគមន៍មូលដ្ឋាន | ព្រៃសម្បទានដីសង្គមកិច្ច ដីសម្បទាន (ឧទាហរណ៍ សម្រាប់ដំណាំកសិផល) | ការកាប់ឈើព្រៃគ្រប់គ្រងដោយនិរន្តរភាព អនុផលព្រៃឈើ | ចំការព្រៃឈើ ឬការដុះឡើងវិញដោយធម្មជាតិជាឈើជាNTFPs ឬជាកាបោន(CDM ឬ អាច REDD) | ព្រៃឈើខូចខាតអាចបានត្រូវដាំឡើងវិញដើម្បីចៀសវាងការបាត់បង់និងសេវាបរិស្ថាន |
| ៥ | ព្រៃឈើឯកជន | សិទ្ធិរបស់អ្នកប្រើប្រាស់ព្រៃឈើរដ្ឋ ឬឯកជន ឬកម្មសិទ្ធឯកជន | គ្រួសារឯកជនក្រោមដីសម្បទានសង្គមកិច្ច | មិនបានបញ្ជាក់ ។ ត្រូវបានបញ្ជាក់ក្នុងសម្បទានសង្គមកិច្ចអំពីដីព្រៃដែលការប្រើប្រាស់ទាក់ទងជាមួយការប្រើប្រាស់ទាក់ទងជាមួយព្រៃឈើ | ចំការដាំឈើសម្រាប់យកឈើ ឬ កាបោន និង NTFPs ដំណាំរួមទាំងកសិរុក្ខកម្ម។ | បច្ចុប្បន្ននេះពុំមានព្រៃឈើឯកជនទេ។ |
| ៦ | ព្រៃអភិរក្ស | រដ្ឋ | ការអភិរក្សមួយចំនួនព្រៃឈើអាចក្លាយជាព្រៃឯកជន ? | គ្មាន ។ ត្រូវបញ្ជាក់សម្បទានសង្គមកិច្ចអំពីដីព្រៃដែលត្រូវការប្រើប្រាស់ទាក់ទងព្រៃឈើ | ចំការឈើដើម្បីយកឈើ ឬកាបោន និងNTFPs។ ឈើកសិផល(ដូចជា កៅស៊ូ ស្វាយ ស្វាយចន្ទី កាហ្វេ ជាដើម)។ កសិរុក្ខកម្ម | ព្រៃឈើខូចខាតត្រូវតែដាំឡើងវិញដើម្បីចៀសវាងបាត់ដី និងសេវាបរិស្ថាន។ |

ព្រៃគុបប្រចាំឆ្នាំគឺជាទម្រង់ការសម្បទានរយៈពេលខ្លី ។ ដូចដែលតម្រូវឱ្យនូវលទ្ធភាពរំលោភធំធេង (មិនប្រកាន់ខ្ជាប់លក្ខខណ្ឌនៃកិច្ចសន្យា) និង ទាមទារកាប់រំលីងមុនការកំណត់ព្រំប្រទល់នៃឡូតិ៍ព្រៃក៏ដូចជាសមត្ថភាពនៃខ្លឹមសារគ្រប់គ្រងរបស់រដ្ឋាភិបាលនៅលើមូលដ្ឋាន (ចំពោះឈើឈរ ឬតំបន់វិភាជន៍ ចំពោះព្រៃគុប) ព្រៃអស់ទាំងនោះមិនសមបើត្រូវបានជ្រើសរើសឡើយ ។

ក្នុងតំបន់ដីត្រូវបានប្រែក្លាយ នៅកន្លែងដែនព្រៃឈើពាណិជ្ជកម្មអាចបម្រើឱ្យការពង្រឹងដល់ការអភិវឌ្ឍន៍សង្គម និងសេវាបរិស្ថានព្រៃឈើ ការដាំដំណាំកសិផលគ្រួសារ (ដូចជាដំណាំកៅស៊ូ) នឹងត្រូវបានជ្រើសរើសសម្រាប់បង្កើនផលិតភាព និងជាប្រយោជន៍ដល់សង្គម ។

ព្រៃសម្បទានទាំងអស់ដែលត្រូវបានព្យួរនឹងត្រូវពិនិត្យឡើងវិញ និងផែនការគ្រប់គ្រងអនុវត្តសមស្របក្នុងគោលបំណងដាំដុះព្រៃឈើឡើងវិញនៅតំបន់ដីព្រៃនៅតំបន់ខូចខាត និងតំបន់ដីព្រៃគ្មានឈើ ។

ការគ្រប់គ្រងដោយជ្រើសរើសទាំងអស់នឹងត្រូវបានគ្រោងនិងអនុវត្តក្នុងន័យយល់ដឹងយេនឌ័រ ។ ដូចជាគន្លឹះនៃការគ្រប់គ្រងទៅអនាគតព្រៃឈើដែលមានតម្លៃខ្ពស់ និងការផ្សំនូវអាកាសធាតុប្រែប្រួលកម្មវិធីអភិរក្សពន្ធុព្រៃឈើត្រូវតែអនុវត្តដើម្បីធានារក្សាទុកគ្រាប់ និងរុក្ខសម្ភារៈសម្រាប់ចំការដាំដុះ និងការដាំដុះលូតលាស់ល្អពី សាកវប្បកម្មដើមកំណើតនៃប្រភេទឈើមានតម្លៃដែលអាចត្រូវគ្នាជាមួយការប្រែប្រួលលក្ខណៈអាកាសធាតុ ។ តម្លៃនៃអនុផលព្រៃឈើគឺទោះជាយ៉ាងណាក៏មានសារៈសំខាន់ផងដែរចំពោះការគ្រប់គ្រងទៅអនាគត ។ ដោយគិតរួមបញ្ចូលគ្នាតម្លៃសេដ្ឋកិច្ចនៃអនុផលព្រៃឈើគឺមានតម្លៃខ្ពស់ ជាពិសេសបើវាមានឥទ្ធិពលទៅលើសុខភាពសាធារណៈហើយនិងប្រាក់កម្រៃទៅអនាគតដែលត្រូវយកចិត្តទុកដាក់ ។ ប្រាក់កម្រៃទៅអនាគតអាស្រ័យទៅលើការបន្តប្រើប្រាស់ ការបង្កើន ការកែច្នៃ និងទីផ្សារនូវផលិតផលគុណភាពខ្ពស់ និងការនាំចេញទៅទីផ្សារផងដែរ (អានឧបសម្ព័ន្ធ ៤) ។

ដូច្នេះ ការយកចិត្តទុកដាក់អនុវត្តជាក់ស្តែងនៃគោលការណ៍នៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពក្នុងផែនការ និងការគ្រប់គ្រងត្រូវតែ :

- យកចិត្តទុកដាក់លើអនុផលព្រៃឈើ ហើយនិងការដែលអាចប៉ះពាល់ការបាត់បង់ ឬការកើនឡើងនៃអនុផលព្រៃឈើទៅលើជីវភាពរស់នៅ និងសេដ្ឋកិច្ច ។
- មើលឃើញរវាងផលប៉ះពាល់ចំពោះប្រជាជនមូលដ្ឋាន និងផលប៉ះពាល់សេដ្ឋកិច្ចទំហំធំធេង(សុខភាពសក្តានុពលនៃការបាត់ការងារធ្វើ ហើយនិងចំណូលពីការនាំចេញ) ។ សក្តានុពលនៃការបាត់បង់ចំពោះសេចក្តីត្រូវការរបស់ប្រជាជនមូលដ្ឋានត្រូវតែឱ្យមានតុល្យភាពទប់ទល់ចំពោះសក្តានុពលនៃផលចំណេញ ចំពោះសង្គមទាំងមូលកំពុងស្ថិតនៅក្រោមការយកចិត្តទុកដាក់អំពីសិទ្ធិប្រជាជនមូលដ្ឋាន។

គំរូដែលចង់បានសម្រាប់ការគ្រប់គ្រងព្រៃឈើត្រូវតែអនុវត្តក្នុងករណីដាំចំការឈើផងដែរ ដែលធ្វើឱ្យកើនឡើងនូវតម្លៃឈើនិងអនុផលព្រៃឈើ ឬទាំងពីរគឺចំពោះប្រជាជនមូលដ្ឋានផង និងចំពោះការទាញយករបស់ឧស្សាហកម្មផង ។

ជំហានដំបូងមួយចំនួនក្នុងការគ្រប់គ្រងព្រៃឈើវិធីដែលធ្វើឱ្យការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពប្រសើរឡើងគឺត្រូវប្រើរយៈពេលវែងហើយពោរពេញទៅដោយជំហានលំបាក១ ។ ការអភិវឌ្ឍន៍មួយចំនួនអាចផ្តល់លទ្ធផលវិជ្ជមាន ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏នៅមានលទ្ធភាពមិនបើកចំហ ។ លទ្ធផលដែលអាចនឹងមានជោគជ័យពីការគ្រប់គ្រងសហគមន៍ព្រៃឈើដែលមានតម្លៃខ្ពស់អាចត្រូវបានវាយតម្លៃ និងពង្រីកយ៉ាងប្រយ័ត្នប្រយែង ។ ដូចគ្នានេះដែរបទពិសោធន៍បានមកពីសហគមន៍ព្រៃឈើ និងដីសម្បទានលើដីព្រៃខូចខាតត្រូវបានប្រើប្រាស់ដើម្បីអនុវត្តកម្មវិធីព្រៃឈើសហគមន៍ជាតិដែលទុកដូចជាជម្រើសមួយក្នុងចំណោមជម្រើសជាច្រើនសម្រាប់ការគ្រប់គ្រងព្រៃឈើ

(កម្មវិធីទី៤នៃកម្មវិធីសហគមន៍ព្រៃឈើជាតិ) ។ ការវិនិយោគទុនក្នុងផលិតកម្មឈើ និងការគ្រប់គ្រងព្រៃឈើត្រូវស្វែងរកប្រតិបត្តិការអន្តរជាតិល្អៗក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ ការធ្វើបែបនេះមិនគ្រាន់តែនាំមកនូវប្រាក់ចំណូលប៉ុណ្ណោះទេតែថែមទាំងជួយដល់ជីវភាពរស់នៅនិងជួយទំនុកបម្រុងដល់ស្ថាប័ន ហើយនិងការបង្កើនសមត្ថភាពផ្ទាល់ខ្លួនផង ។ វែងឆ្ងាយទៅទៀតនោះវានឹងនាំនូវមេរៀនដែលត្រូវរៀនសូត្រដើម្បីប្រតិបត្តិការផ្សេងៗហើយពិតណាស់សម្រាប់ការងារដោយទៀងទាត់ ។ កម្មវិធីព្រៃឈើជាតិ ស្នើរដ្ឋាភិបាលយកចិត្តទុកដាក់បើកឱ្យឯកជនកម្មសិទ្ធករគ្រួសារតូចតាចទទួលដីព្រៃដូចកម្មសិទ្ធឯកជនទទួលដីកសិកម្ម ។ ព្រៃឈើត្រូវតែគោរពតាមគោលការណ៍ការគ្រប់គ្រងព្រៃឈេដោយនិរន្តរភាព ។

### ៥.២ ការតាមដាន និងតម្លាភាព :

ការតាមដាននិងការភ្ជាប់ទៅនឹងតម្លាភាពគឺជាគន្លឹះដើម្បីអនុវត្តកម្មវិធីព្រៃឈើជាតិ ហើយនិងយុទ្ធសាស្ត្រចំពោះការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ក្នុងការស្វែងរកទីផ្សារដែលឱ្យតម្លៃខ្ពស់ដូចជាឈើមានវិញ្ញាបនកម្ម និងការចាប់យកកាបោន ។ ប្រព័ន្ធប្រសិទ្ធភាពនៃការតាមដាន និងការវាយតម្លៃដូចជាភាគទាំងមូលនៃកម្មវិធីព្រៃឈើជាតិ ហើយកម្មវិធីព្រៃឈើជាតិមិនអាចចាត់ទុកថាយុទ្ធសាស្ត្រស្ថិតនៅក្រៅប្រតិបត្តិការទេ ។

ការតាមដាននឹងរួមបញ្ចូលគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍន៍ ដូចជាផលិតកម្មព្រៃឈើ ជីវចម្រុះ ការរក្សាទុកកាបោន ការប្រើប្រាស់ដីធ្លី សម្បទានពាណិជ្ជកម្ម ការអនុវត្តច្បាប់ ការដោះស្រាយទំនាស់ សូចនាករសង្គម និងបរិស្ថាន និងការចែកចាយផលប្រយោជន៍ជាដើម ។ សូចនាករ និងឧបករណ៍សម្រាប់ប្រមូលផ្តុំពត៌មានអំពីស្ថានភាពទាំងឡាយ ដែលត្រូវអភិវឌ្ឍន៍ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធរួមទាំងសហគមន៍ ។

រាល់ពត៌មានបានមកពីការតាមដានកត់ត្រាគឺជាប្រយោជន៍ដល់រាជរដ្ឋាភិបាលកម្ពុជាដល់អ្នកវិនិរយោគ និងសាធារណៈ ។

### ៥.៣ ការបង្កើនសមត្ថភាព :

រាជរដ្ឋាភិបាលកម្ពុជាលើកសរសើរថារដ្ឋបាលព្រៃឈើត្រូវការរចនាសម្ព័ន្ធមួយដែលអនុញ្ញាតឱ្យគេទទួលខុសត្រូវ និងផ្សាំ ទៅនិងការប្រែប្រួលអាកាសធាតុ ហើយនិងមានលទ្ធភាពក្នុងការអនុវត្តន៍ត្រឹមត្រូវនូវនយោបាយ ផែនការ និងកម្មវិធីនានាស្របតាមអាណត្តិនិតិបញ្ញត្តិ ។ ទោះជាយ៉ាងនេះក៏ដោយក៏រាជរដ្ឋាភិបាលកម្ពុជាអបអរថាការបង្កើនសម្ថភាពត្រូវតែឆ្លងកាត់តាមពហុអង្គការជាតិ និងពហុស្ថាប័ន ហើយមិនមែនតែរដ្ឋបាលព្រៃឈើមួយនោះទេ ។

ការគ្រប់គ្រងធនធានព្រៃឈើដោយនិរន្តរភាពតម្រូវឱ្យមានការជឿជាក់របស់ស្ថាប័ន និងសមត្ថភាពខ្ពស់ក្នុងជួរថ្នាក់ដឹកនាំ ។ ការរៀបចំឱ្យមានការជឿជាក់កើត ឡើងពីវិធីសាស្ត្រនៃស្ថាប័នដែលត្រូវផ្តោតទៅលើបញ្ហាជាយុទ្ធសាស្ត្ររៀបចំជាមួយសេនាធិការដែលមានបច្ចេកទេស និងសមត្ថភាពជាយុទ្ធសាស្ត្រក៏ដូចជាការជម្រុញឱ្យអនុវត្តជាដំបូង

មុនសកម្មភាពនិយម និងកិច្ចការទាំងឡាយដែលជួយទំនុកបម្រុងដល់ការគ្រប់គ្រងធនធានព្រៃឈើ និងសារព័ន្ធ។ វាមានសារសំខាន់ណាស់ដែលរដ្ឋបាលព្រៃឈើ និងអង្គភាពផ្សេងៗរបស់រជារដ្ឋាភិបាលបញ្ចេញឱ្យឃើញតាមរយៈគោលការណ៍ និងអាទិភាព ។ សកម្មភាពណាមួយដែលអាចមានហានិភ័យចំពោះធនធានព្រៃឈើជាតិ និង/ឬសហគមន៍ត្រូវតែបានកំណត់សកម្មភាពមុន ហើយនិងសង្គមត្រូវតែប្រុងប្រៀបដើម្បីទប់ស្កាត់អំពើទាំងនោះក៏ដូចជាជួយធ្វើឱ្យបានកាន់តែច្បាស់លាស់ឡើងនូវអាទិភាពរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលកម្ពុជាប្រាថ្នាធានាថាផែនការ និងកម្មវិធីអភិវឌ្ឍន៍ត្រូវបានប្រគល់ឱ្យអ្នកដែលមានចំណេះដឹងគ្រឹះខ្ពស់ខាងលើដែលប្រាប់សេចក្តីសម្រេចធ្វើបាន និងសកម្មភាពអភិវឌ្ឍន៍ការវិនិយោគទៅអនាគត ។ ការគ្រប់គ្រងបែបនេះវាជាផលប្រយោជន៍ចំពោះប្រជាជនកម្ពុជាទាំងអស់ជាយថាហេតុ ។ ដើម្បីធ្វើឱ្យបានសម្រេចកម្មវិធីនេះរាជរដ្ឋាភិបាលទទួលស្គាល់ថាការបង្កើនសមត្ថភាពឱ្យបានមធ្យ័តជាតម្រូវការចាំបាច់ ។ ដើម្បីទទួលលទ្ធផលគាប់ចិត្តក្នុងការបង្កើនសមត្ថភាពវាជាអាជ្ញាបញ្ហាដែលស្ថាប័នជាតិប្រគល់ការជ្រើសរើសមកឱ្យរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ហើយនិងខេត្តក៏ដូចជាខណ្ឌរដ្ឋបាលអាចមានលទ្ធភាពជួយដល់ការជ្រើសរើសចំនួនបុគ្គលិកឱ្យមានគុណភាព ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថានេះវាហាក់ដូចជាចំណុចខ្សោយមួយក្នុងចំណោមចំណុចខ្សោយទាំងអស់នៃបរិយាកាសអប់រំ ហើយអាចបង្កឱ្យមានហានិភ័យឱ្យកាន់តែធំឡើងចំពោះការអនុវត្តន៍ជោគជ័យនៃកម្មវិធីព្រៃឈើជាតិ ហើយនិងទស្សនៈវិស័យរយៈពេលវែង ។

ហេតុដូច្នេះ ត្រូវតែប្រមូលផ្តុំកម្លាំងឆ្ពោះទៅជួយស្ថាប័នអប់រំគ្រប់គ្រងធនធានធម្មជាតិឱ្យមានកម្រិតមួយដែលស្ថាប័នទាំងនេះអាចប្រគល់សមត្ថភាពជ្រើសរើសឆ្លងកាត់ប្រធានបទដ៏ធំធេងនេះ ។ ប្រធានបទនេះនាំមកនូវការចាំបាច់ចំពោះរាល់បញ្ហាទាំងអស់ដែលកើតមកពីព្រៃឈើបរិសុទ្ធ និងបុគ្គលិកគ្រប់គ្រង ហើយនិងការអភិវឌ្ឍន៍អភិបាលកិច្ច និងសេវាកមស៊ីវិល វនវប្បកម្ម ឬការដាំឈើបរិស្ថានដើម្បីអភិរក្សពន្ធ និងសេនេទិក ឬពូជបច្ចេកវិទ្យាឈើហើយនិងរៀនសូត្រដោយធ្វើតាមការអនុវត្តន៍និងការវិវត្តន៍ថ្មីខ្វែងតំបន់ព្រមទាំងការធ្វើសហប្រតិបត្តិការប្រកបដោយតម្លាភាព និងការប៉ិនប្រសប់ខាងការសម្របសម្រួល ។

ដោយធ្វើការគាំទ្រចំពោះវិស័យអប់រំរាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថា និងអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សឱ្យបានខ្ពង់ខ្ពស់ដើម្បីទំនុកបម្រុងដល់វិស័យ ព្រៃឈើក៏ដូចជាក្រើនរំលឹកបុគ្គលិកប្តូរវេនឱ្យមានចិត្តឆ្ពោះទៅរកសកម្មភាពការងារច្បាស់លាស់ដើម្បីបង្កើនទិន្នផល ។ បញ្ហានេះមានសារសំខាន់ណាស់ចំពោះជាតិទៅអនាគតហើយមិនដឹងជាពេលណាកើតមានឡើងនូវការប្រណាំងប្រជែងក្នុងផលប្រយោជន៍អាចកើតឡើងនៅទីផ្សារអន្តរជាតិ ។ ភាគនៃការប្រែប្រួលនេះត្រូវតែធ្វើឱ្យបានសម្រេចដោយបង្កើនសហប្រតិបត្តិការអន្តរ-ស្ថាប័ន និងការអភិវឌ្ឍន៍របៀបរៀបរយក៏ដូចជាការតាមដាន ។ សមត្ថភាពសម្រាប់ធ្វើការងារនេះត្រូវតែ កសាងឡើងដោយការខិតខំដល់កម្រិតកំពូល ។ ជាមួយការបម្រើឱ្យធនធានធម្មជាតិ ភាពលូតលាស់សេដ្ឋកិច្ចជាវិជ្ជមាន ការលូតលាស់សង្គម និងបរិស្ថាននោះវានឹងលេចឡើងយ៉ាងពិតប្រាកដ ។ កម្មវិធីព្រៃឈើជាតិមានមហិច្ឆតា និងការប្រណាំងប្រជែងធំមួយចំពោះកម្ពុជា ។ ហេតុនេះវាជាបញ្ហាមួយសំខាន់ណាស់ដែលគោលដៅប្រកាសរួចនឹងត្រូវបាន

សម្រេចដូចដែលបានគ្រោង ហើយសមត្ថភាពដែលបម្រើការងារត្រូវឱ្យមាននៅហ្នឹងកន្លែង ។ រាជរដ្ឋាភិបាលអបអរ ចំពោះសារសំខាន់នៃការ "វិនិយោគក្នុងវិស័យអប់រំ" ហើយមើលឃើញថាវាហាក់ដូចជាអាទ្បាបញ្ហាដើម្បីដោះស្រាយ អភិវឌ្ឍន៍ឱ្យបានជោគជ័យ ។

## ៦. កម្មវិធីអនុវត្តន៍កម្មវិធីព្រៃឈើជាតិ

កម្មវិធីអនុវត្តន៍របស់កម្មវិធីព្រៃឈើជាតិ ចំនួន៦ត្រូវបានផ្តល់យុទ្ធសាស្ត្រ និងផ្លូវអនុវត្តន៍ចំពោះអាទិភាព ដែលបានដាក់ចេញសម្រាប់ដឹកនាំយុទ្ធសាស្ត្រទាំងនេះ ។

កម្មវិធីនីមួយៗមានផែនការសកម្មភាពរយៈពេលខ្លី(៥ឆ្នាំ) ដែលទុកដូចជាមធ្យោបាយសម្រាប់ឱ្យកម្មវិធីព្រៃឈើ ជាតិក្លាយទៅជាមានដំណើរការពិតប្រាកដ ។ ផែនការសកម្ម ភាពទាំងនេះផ្សារភ្ជាប់ជាមួយការអង្រិកទៅអនាគត នូវផែនការសកម្មភាពបច្ចុប្បន្ន (២០០៧-២០១០) នៃក្រុមអនុវត្តការងារ និងបរិស្ថាន នៅពេលដែលបញ្ចូលភាគ ទាំងអស់ទៅក្នុងផែនការនេះមិនបានសម្រេច ។

**កម្មវិធីមានដូចតទៅ :**

១-ការកំណត់ព្រំប្រទល់ព្រៃឈើជាតិ ការចាត់ថ្នាក់ និងការចុះបញ្ជីកា

១-អនុកម្មវិធី ១-១- ការកំណត់ព្រំប្រទល់ព្រៃឈើ និងការចុះបញ្ជិការ ។

២-អនុកម្មវិធី ១-២- ការចាត់ថ្នាក់ព្រៃឈើជាតិ ។

២-ការគ្រប់គ្រងធនធានព្រៃឈើជាតិ និងកម្មវិធីអភិរក្ស

១-អនុកម្មវិធី ២-១- ផែនការគ្រប់គ្រងព្រៃឈើជាតិ ។

២-អនុកម្មវិធី ២-២- ការពង្រីកការតាមដាន ការវាយតម្លៃ និង ការធ្វើរបាយការណ៍អំពីការគ្រប់គ្រង ព្រៃឈើដោយនិរន្តរភាព ។

៣-អនុកម្មវិធី ២-៣- ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើផលិតកម្មក្រៅព្រៃឈើសហគមន៍ ។

៤-អនុកម្មវិធី ២-៤- ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ជីវចម្រុះសម្រាប់តំបន់ការពារ ។

៥-អនុកម្មវិធី ២-៥- ការអភិរក្សធនធានពន្ធុពូជ (សេនេទិក) បានមកពីព្រៃឈើ និង ការបង្កើតប្រភព គ្រាប់ពូជសម្រាប់កម្មវិធីដាំដុះ ។

៦-អនុកម្មវិធី ២-៦- ការអភិវឌ្ឍន៍ចំការដាំឈើសម្រាប់ពហុគោលបំណង ។

៧-អនុកម្មវិធី ២-៧- ការកែច្នៃផលិតផលព្រៃឈើនៅមូលដ្ឋាន និងការផ្សព្វផ្សាយទីផ្សារ ។

៨-អនុកម្មវិធី ២-៨- ការកែច្នៃឈើ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឈើ ។

៣-ការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ និងកម្មវិធីអភិបាលកិច្ច

១-អនុកម្មវិធី ៣-១- ការកែទម្រង់នីត្យានុកូល និងរដ្ឋបាល ។

២-អនុកម្មវិធី ៣-២- ការអនុវត្តន៍ច្បាប់ និងការតាមដានឧក្រិដ្ឋកម្មព្រៃឈើ និងការធ្វើរបាយការណ៍ ។

៣-អនុកម្មវិធី ៣-៣- ការឆ្លើយតបភ្លាមៗ អំពីពតិមានឧក្រិដ្ឋកម្មព្រៃឈើ ។

៤-កម្មវិធីព្រៃឈើសហគមន៍ជាតិ

១-អនុកម្មវិធី ៤-១- ការកំណត់អត្តសញ្ញាណសហគមន៍ព្រៃឈើ និងភាពជាក់លាក់ ។

២-អនុកម្មវិធី ៤-២- ការអភិវឌ្ឍន៍សហគមន៍ ស្ថាប័ន និងជីវភាពរស់នៅ ។

៣-អនុកម្មវិធី ៤-៣- ការពង្រីកការគាំទ្រសហគមន៍ព្រៃឈើ ។

៥-កម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងការស្រាវជ្រាវ

១-អនុកម្មវិធី ៥-១- ការអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស ។

២-អនុកម្មវិធី ៥-២- ការពង្រីក និងសមជ្ឈញ្ញៈសាធារណៈ ។

៣-អនុកម្មវិធី ៥-៣- ការអភិវឌ្ឍន៍សមត្ថភាពនៃការស្រាវជ្រាវ ។

៤-អនុកម្មវិធី ៥-៤- វិញ្ញាបនកម្មព្រៃឈើ ។

៦-កម្មវិធីហិរញ្ញវត្ថុព្រៃឈើ